មជ្ឈមណ្ឌលឯកសារកម្ពុជា

**សម្ភាសន៍ជាមួយ វឿន សៀន ហៅស៊ុន សំណាង ភេទប្រុស អាយុ៥៤ឆ្នាំ**

**មុខងារសម័យខ្មែរក្រហមៈ“និរសា”**

**កើតនៅ ភូមិស្រែឫស្សី ឃុំសម្រោង ស្រុកស្ទឹងត្រែង ខេត្តស្ទឹងត្រែង**

**សព្វថ្ងៃរស់ ភូមិត្រពាំងប្រាសាទ ឃុំត្រពាំងប្រាសាទ ស្រុកត្រពាំងប្រាសាទ**

**ខេត្តឧត្តរមានជ័យ**

**ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៣**

**សម្ភាសន៍ដោយៈ សោម ប៊ុនថន**

**០២:១៤ :៥១**

**៥០ ទំព័រ**

ថនៈ សុំថតសម្លេងពូ ពូ! អនុញ្ញាតទេ?

សៀនៈ បាទ! ខ្ញុំឈ្មោះ វឿន សៀន សមាជិកក្រុមប្រឹក្សាស្រុកត្រពាំងប្រាសាទ ។

ថនៈ ពូមានឈ្មោះអីហៅក្រៅទៀតទេ ពូ?

សៀនៈ ឈ្មោះហៅក្រៅ ស៊ុន សំណាង ។

ថនៈ ស៊ុន សំណាង!

សៀនៈ បាទ!

ថនៈ ឈ្មោះហ្នឹង ដូរហៅក្រៅតាំងពីណាមកពូ?

សៀនៈ ខ្ញុំមកកាន់សារព័ត៌អញ្ចឹង ក៏ដាក់ឈ្មោះ ស៊ុន សំណាងផ្សេង ។

ថនៈ ខាងសារព័ត៌នៅអ៊ំ?

សៀនៈ នៅរស្មីអង្គរ ។

ថនៈ ហ្នឹងជាកាសែត ឬអីពូ?

សៀនៈ នេះរបស់ខ្ញុំ ។

ថនៈ ចុះមួយខែ ប៉ុន្មានលេខពូ?

សៀនៈ បានខ្ញុំចុះមួយ អាទិត្យមួយលេខ ។

ថនៈ មួយអាទិត្យ មួយលេខ?

សៀនៈ បាទ!

ថនៈ តាស្រុកឧត្តរមានជ័យយើងទេ ឬក៏ស្រុកផ្សេងទៀត ឬក៏?

សៀនៈ ស្រុកផ្សេងក៏បាន ឲ្យតែខេត្តឧត្តរមានជ័យហ្នឹង ព្រោះខ្ញុំកាន់ មួយខេត្តហ្នឹង ។

ថនៈ ពូ! អាយុប៉ុន្មានហើយសព្វថ្ងៃហ្នឹង?

សៀនៈ អាយុខ្ញុំ៥៨ ។

ថនៈ ពូ មានស្រុកកំណើតនៅភូមិឃុំអីដែរ?

សៀនៈ ស្រុកកំណើតនៅខេត្តស្ទឹងត្រែង ។

ថនៈ ភូមិអីដែរពូ?

សៀនៈ ភូមិស្រែឫស្សី ។

ថនៈ ស្រែឫស្សី?

សៀនៈ បាទ!

ថនៈ ឃុំពូ?

សៀនៈ ឃុំសម្រោង ។

ថនៈ ស្រុក?

សៀនៈ ស្ទឹងត្រែង ។

ថនៈ បច្ចុប្បន្ន ពូនៅភូមិឃុំអីដែរ?

សៀនៈ បច្ចុប្បន្ននៅ ភូមិត្រពាំងប្រាសាទ ឃុំត្រពាំងប្រាសាទ ស្រុកត្រពាំងប្រាសាទ ។

ថនៈ នៅជិតនេះដែរពូ?

សៀនៈ បាទ! នៅខាងត្បូងផ្សារ ។

ថនៈ នៅជិតផ្ទះអ៊ំសារិននេះដែរ?

សៀនៈ បាទ! នៅខាងត្បូងនេះដែរ ជាប់០១១ ។

ថនៈ ពូមានបងប្អូន ប៉ុន្មាននាក់ដែរពូ?

សៀនៈ បងប្អូន៦នាក់ ។

ថនៈ ប្រុសប៉ុណ្ណា ស្រីប៉ុន្មាន?

សៀនៈ ប្រុស២ ស្រី៤ ។

ថនៈ ពូកូនទីប៉ុន្មាន?

សៀនៈ ខ្ញុំកូនទី២ ។

ថនៈ ពូកូនទី១ ឈ្មោះអីដែរពូ?

សៀនៈ កូនទី១ឈ្មោះ ស៊ិន, វឿង ស៊ិន ។

ថនៈ ប្រុសហ៎ពូ?

សៀនៈ ស្រី ។

ថន:     បច្ចុប្បន្ន គាត់រស់នៅឯណាទៅ?

សៀន: បច្ចុប្បន្ន គាត់រស់នៅឯស្រុក ។

ថន:     ស្រុកស៊ឹងត្រែង?

សៀន: បាទ!

ថន:     ទី៣?

សៀន: រឿន សៀក ។

ថន:     ប្រុស?

សៀន: បាទ!

ថន:     នៅឯណាដែរណាពូ?

សៀន: នៅស្រុកទាំងអស់គ្នា ។

ថន:     ហ្នឹងអើស្រី?

សៀន: ស្រី!

ថន:     គាត់នៅស៊ឹងត្រែងដែរ?

សៀន: ស៊ឹងត្រែង ។

ថន:     ទី៤?

សៀន: រឿន ដម ។

ថន:     ដម អីពូ?

សៀន: បាទ! ដម ។

ថន:     ស្រី! ស៊ឹងត្រែងដែរ ។ ទី៥?

សៀន: ឈ្មោះ អាកុសល ។

ថន:     កុសល ។

សៀន: វាប្រុស ។

ថន:     ស៊ឹងត្រែង?

សៀន: បាទ!

ថន:     ពូទី៣?

សៀន: បាទ!

ថន:     ទី៦?

សៀនៈ វឿង សារុំ?

ថនៈ អាហ្នឹងស្រីហ៉ប៉ូ?

សៀនៈ ស៊ឹងត្រែង?

ថនៈ ពូ ចុះឪពុកម្ដាយពូនៅស្រុកទេ?

សៀនៈ ឪពុកខ្ញុំស្លាប់ ពីឆ្នាំ ១៩៧៤ ។ ហ្នឹងដែរ?

ថនៈ ស្លាប់ដោយសារអី?

សៀនៈ ស្លាប់ដោយសារជំងឺ ។

ថនៈ ស្លាប់នៅស៊ឹងត្រែង?

សៀនៈ ជំនាន់យើង វាយលន់ នល់ ។ ឈ្មោះ វឿង ស៊ិន ។ ឪពុកខ្ញុំឈ្មោះ ស៊ិន ។

ថនៈ បើមកដល់សព្វថ្ងៃនេះ គាត់អាយុប្រហែលជាប៉ុន្មាន?

សៀនៈ មិនដឹងជាអាយុប៉ុន្មាន បើម្ដាយពេទ្យ អាយុ៨៨ឆ្នាំ ប៉ុន្តែឪពុក មិនដឹងជាអាយុប៉ុន្មានទេ ។

ថនៈ គាត់អាយុបងម្ដាយពូ មានអាយុ!

សៀនៈ បាទ! បងម្ដាយខ្ញុំ ។

ថនៈ អញ្ចឹង ប្រហែលជាជិត៩០ ហើយមើលទៅ ។

សៀនៈ បើអ៊ីខ្ញុំអាយុ១០៥ឆ្នាំ ហើយមិនទាន់ស្លាប់ ដែលអ៊ីបងម្ដាយខ្ញុំ ។

ថនៈ នៅរស់ដល់សព្វថ្ងៃពូ?

សៀនៈ បាទ!

ថនៈ នៅក្រចេះអី?

សៀនៈ នៅស៊ឹងត្រែង ។

ថនៈ នៅរស់បានប៉ុណ្ណឹង ស្រុកខ្មែរ?

សៀនៈ ប៉ុន្តែគាត់ថ្លង់ ។

ថនៈ តែគាត់នៅមើលច្បាស់?

សៀនៈ មើលទាល់តែជិត!

ថនៈ មើលស្គាល់ទេ កូនចៅ?

សៀនៈ ស្គាល់ ។ គាត់សំលៀងកាំបិត សំលៀងអីបានទាំងអស់ ។

ថនៈ គាត់អត់វង្វេងទេ?

សៀនៈ អត់វង្វេងទេ ។

ថនៈ   កម្រនៅស្រុកខ្មែរ ។

សៀនៈ ឪពុកខ្ញុំស្លាប់ហ្នឹង ខ្ញុំចេញមក មកតស៊ូ មកនៅជាមួយពូខ្ញុំ ប៉ុនពូស្លាប់បាត់ហើយឥឡូវ ។

ថនៈ   ចុះម្ដាយពូឈ្មោះអីវិញ?

សៀនៈ ប៉ុនមិនដឹងជាត្រកូលឈ្មោះអីទេ! ឈ្មោះតាន ។

ថនៈ   ម្ដាយតាន ។ គាត់ឥលូវអាយុ៨០?

សៀនៈ ៨៨ហើយ ។

ថនៈ   ៨៨?

សៀនៈ បាទ!

ថនៈ   ពូបានរៀនសូត្រដល់ថ្នាក់ណាដែរ?

សៀនៈ ដល់ថ្នាក់ទី១១ ពីដើម ពីសង្គម!

ថនៈ   ចូលរៀនឆ្នាំណាពូ?

សៀនៈ ឆ្នាំ៧៣ ។

ថនៈ   នៅសាលាណាពូ?

សៀនៈ នៅសាលាក្នុងព្រៃ នៅសាលាក្នុងព្រៃតែម្ដង ព្រៃម៉ាគី ពួនក្នុងព្រៃតែម្ដង ។

ថនៈ   អ៊ូ! ពូចូលព្រៃហើយ បានពូរៀន?

សៀនៈ បាទ! រៀនក្នុងព្រៃហើយ បានរៀនដុតភ្លើងចល្ដុះ ។

ថនៈ   អញ្ចឹង ពូអាចរៀបរាប់បានទេពូ?

សៀនៈ កាលខ្ញុំរៀនហ្នឹងគ្រូ ខ្ញុំឈ្មោះ គ្រូញ៉ុយ ប៉ុន្តែគាត់ស្លាប់ហើយ ។

ថនៈ   គាត់ខាងបដិវត្តន៍ដែរ?

សៀនៈ បាទ! បដិវត្តន៍ ។

ថនៈ   ពូចូលបដិវត្តន៍ឆ្នាំប៉ុន្មាន?

សៀនៈ ខ្ញុំចូលឆ្នាំ ១៩៧៤ ។ ឪពុកខ្ញុំស្លាប់ខែ៤ហ្នឹង ។ ថ្ងៃទី១ ខែ៤,១៩៧៤ ។ ខ្ញុំ ពូខ្ញុំឈ្មោះ ពូខាំ គាត់ណេវទាហានតំបន់ណា កាលនោះវាយជាមួយទាហានលន់ នល់ យកមកនៅរែក បាយ ជូនមកសមរភូមិ ឲ្យកងទ័ពនៅតូច ។

ថនៈ   កាលនោះពូអាយុប៉ុន្មានហើយ គាត់យកមក?

សៀនៈ កាលនោះ អាយុ១៣,១៨ឆ្នាំ ខ្ញុំអត់ចាំ ឥលូវ៥៤ហើយ តាំងពី៧៤មក។ បានខ្ញុំចេញពីហ្នឹង រំដោះ៧៥មក ខ្ញុំនៅកងតំបន់ ខ្ញុំទៅនៅកងតំបន់ព្រំដែនឆ្នាំ ៧៦, ៧៧ហ្នឹង ខ្ញុំទៅនៅព្រំ ដែន អូរតាង៉ូវ ។ អូរតាង៉ូវ ខាងយើងព្រំដែនលាវនោះ យើងតាមដងទន្លេសេកុង!

ថនៈ ហ្នឹងនៅស្រុកអីវិញ?

សៀនៈ ហ្នឹងស្រុកសៀម ប៉ាង ។ ស្រុកសៀមប៉ាង ខេត្តស្ទឹងត្រែង កាលហ្នឹងទៅប្រចាំព្រំប្រទល់លាវ ហើយហ្នឹងកម្ពុជាឆ្នាំ៧៦, ៧៥, ៧៧ ខ្ញុំមកនៅហុលមាន កោះដាប មកជិតផ្ទះបងស៊ុមនៅ ស្រុកសៀមប៉ាងយើងហ្នឹង ព្រំប្រទល់លាវដូចគ្នា ។

ថនៈ ចុះពូ ចង់សួរបកទៅក្រោយ?

សៀនៈ ពូ របស់ពូហ្នឹង គាត់នៅកងតំបន់ តំបន់ប៉ុន្មានពូ?

ថនៈ តំបន់១០៤?

សៀនៈ បាទ! ព្រោះខាងព្រះវិហារតំបន់១០៣ ។

ថនៈ បាទ! ខាងប្រះវិហារតំបន់១០៣ ។

សៀនៈ កាលនោះ គេហៅតំបន់១០៤, ១០៣ ហើយកាលនោះក្រចេះ គេហៅតំបន់ស្វ័យតណ៌ ខេត្តក្រចេះ ។

ថនៈ ១០៤ហ្នឹង នៅក្នុងភូមិភាគឦសាន ឬក៏ដាច់ដោយឡែកហ្នឹងភាគឦសាន?

សៀនៈ ភូមិភាគឦសានហ្នឹងហើយ ភូមិភាគ១ ។

ថនៈ ភូមិភាគ១?

សៀនៈ បាទ! ភូមិភាគ១ហ្នឹង ភូមិភាគឦសាន ។ ខេត្តស្ទឹងត្រែងហ្នឹង គេហៅតំបន់ពីជំនាន់ខ្មែរ ក្រហម ។

ថនៈ តំបន់១០៤ ។ មានប៉ុន្មានតំបន់ពូ នៅឦសាន?

សៀនៈ មានតំបន់១០៣, ១០៤, ១០៣នេះ ព្រះវិហារ កាលនោះតំបន់ស្វ័យព្រះវិហារនោះកាល ហ្នឹងនោះ ។ ១០៤ តំបន់នែក ១០២, ១០២ រតនគិរី ។

ថនៈ ១០២ រតនៈគិរី?

សៀនៈ បាទ! មណ្ឌលគិរីមិនដឹង១០០ប៉ុន្មានទេភ្លេចបាត់ហើយ ។ ខ្ញុំដឹងត្រឹមតែរតនគិរីតំបន១០០២ ព្រះវិហារ១០៣ ។

ថនៈ ១០៤ ស្ទឹងត្រែងនែក ពូណ៌?

សៀនៈ បាទ!

ថន: កាលហ្នឹងគណៈតំបន់នរណាពូ?

សៀន: កាលហ្នឹង គណៈតំបន់ឈ្មោះ តា ប៊ុត ។ មេភូមិភាគមួយឈ្មោះ តា វ៉ន ។

ថន: តា វ៉នហ្នឹងក្រោយទេពូ?

សៀន: តា ឌុច! ខ្ញុំស្គាល់ត្រឹមតែតា វ៉ន! តាឌុច, តាយ៉ា ។

ថន: តាយ៉ាអី?

សៀន: ខ្ញុំភ្លេចតែចៅហ្វាយស្រុកៗ ហើយស្រុកស៊ីនត្រែង ឈ្មោះ តា ចក់ ។

ថន: តា វ៉ន គាត់មកក្រោយទេពូ?

សៀន: តា វ៉ននេះយូរហើយ ។ តា វ៉នហ្នឹង គាត់នៅកាន់ភូមិភាគ១ហ្នឹង តាំងពីខ្ញុំមកនៅ ស៊ីនត្រែង មក ហើយគាត់មកកាន់ភូមិភាគ ពីមុនមិនដឹងនរណា ។ ពីមុនឈ្មោះ តានេះមកពី វៀតណាម នោះ ឈ្មោះតា ចែម ។

ថន: បាទ! នេះក្នុងសៀវភៅ ។ ណៃ សារ៉ាន់ ហៅយ៉ា ។

សៀន: បាទ! តា យ៉ា ហើយ តា វ៉នកាលនោះ ។

ថន: មានតំបន់១០១, តំបន់១០២, តំបន់១០៤, តំបន់១០៥, តំបន់១០៧ និងតំបន់ ៥០៥ ។

សៀន: តំបន់៥០៥ហ្នឹង ខេត្តក្រចេះមិនដឹង ឬក៏មណ្ឌលគិរី?

ថន: នេះខ្ញុំនៅអត់សូវច្បាស់ដែរពូ ។

សៀន: ខ្ញុំដឹងតែប៉ុន្មានតំបន់ ព្រោះខ្ញុំឡើងមកព្រំដែនកាលហ្នឹង បាទ! ពុំសូវដឹង ។

ថន: ពូខាំហ្នឹង ពូរបស់ពូបង្កើត?

សៀន: គាត់មេទាហាន មេទាហានតំបន់ ។

ថន: មេតំបន់?

សៀន: កាលហ្នឹងគេហៅកងធំ កាលនោះគេហៅប្រធានគ-សព្វថ្ងៃ ។

ថន: គាត់នៅប្រធានគ- ហ្នឹងកងប៉ុន្មានពូ?

សៀន: អើ! ៧០៥ តំបន់៧០៥នេះ គេហៅវរៈ៧០៥ ។

ថន: វរសេនាតូចហ៎?

សៀន: វរសេនាតូច ៧០៥ ប៉ុន្តែប្រធានវរសេនាតូចឈ្មោះ ដែលបងថ្លៃខ្ញុំប្រធានវរឈ្មោះ ធី ហៅ សា ប៉ុនគេយកទៅសម្លាប់ចោលអស់ហើយ ។

ថន: ហ្នឹងគាត់ ប្រធានវរៈ៧០៥?

សៀនៈ បាទ! ធី ហៅ សា ។

ជនៈ គេចាប់ដែរឬ?

សៀនៈ បាទ! គេសម្លាប់ ។

ជនៈ ដែលសម្លាប់ហ្នឹង ខ្ញុំស្គាល់អ្នកសម្លាប់ទៀត ។

សៀនៈ នៅឆ្នាំណាឬ?

ជនៈ សម្លាប់ដែលឆ្នាំដែលវៀតណាមចូលមក ។

សៀនៈ សម្លាប់ដែលឆ្នាំ វៀតណាមចូលមកនោះ ឆ្នាំ១៩៧៨ ដើម៧៨ ក្នុងខែប៉ុន្មានទេ ភ្លេចបាត់ហើយយួនចូលមក ។

ជនៈ ខាងណាសម្លាប់? ខាងវៀតណាម ឬមួយក៏ខាង?

សៀនៈ ខាងយើងហ្នឹងឯងសម្លាប់ ថាគាត់ក្បត់នៅអង្គការគេទៅ គេសម្លាប់ ។ សម្លាប់នៅរស់គាសព្វថ្ងៃ ។

ជនៈ គេយកមកណាវិញ គេមកសម្លាប់?

សៀនៈ សម្លាប់នៅអូរស្វាយយើង ទន្លេមេគង្គ ។

ជនៈ កន្លែងហ្នឹងជាមន្ទីរសន្តិសុខ ឬក៏?

សៀនៈ អត់ទេ! ព្រៃ ។ អាហ្នឹងភូមិអ្នកស្រុក គេហៅភូមិអូរស្វាយ ដាក់ឃុំអូរស្វាយ ឃុំហ្នឹងនៅមាត់ទន្លេមេគង្គ ។

ជនៈ ហ្នឹងបញ្ជាពីថ្នាក់លើឲ្យសម្លាប់ ឬមួយក៏យ៉ាងមេ៉ច?

សៀនៈ ត្រឹមគណៈតំបន់ តំបន់ថ្មី ។

ជនៈ គណៈតំបន់ថ្មី?

សៀនៈ បាទ!

ជនៈ គណៈតំបន់ថ្មីហ្នឹង ពីណាឬ?

សៀនៈ ឈ្មោះ តាវឿន ។ នៅកងពលលេខ៨ ពីមុនគាត់គណៈតំបន់ កាលហ្នឹងខ្ញុំចេញពីទាហានមក គេថាគេរើសពួកខ្ញុំនៅកងតំបន់ហ្នឹង៧នាក់ គេថារើសអ្នកប្រវត្តិរូបល្អៗអញ្ជឹងណា ទៅបើកយន្តហោះ ។ បើកយន្តហោះ ទៅមក១ គេស្រាវជ្រាវប្រវត្តិរូប ខ្ញុំក៏អត់បានទៅពីអ្នក ឈ្មោះអារំសាយ ហើយអារំសាយនោះវានៅប៉ៃលិន ធ្វើមេភូមិ! ប៉ុនមិនដឹងថាឥលូវ គាត់ឈប់ធ្វើមេភូមិ ឬនៅ ។ គេដកខ្ញុំពីនាក់វាមកទុកនៅក្រៅនៅមន្ទីរភ្នំបាំង កងតំបន់ហ្នឹងឯង គ្រាន់តែតំបន់ពួកខ្ញុំហ្នឹង គេហៅពួកមន្ទីរ ពួកមន្ទីរហៅក្រសួងមន្ទីរហ្នឹងណាស់ ទៅដកអញ្ចឹងក្រៅពីនោះគេបាន

ទៅភ្នំពេញទៅ ខ្ញុំពីរនាក់គេដកទៅ គេស្រាវជ្រាវថាប្រវត្តិខ្ញុំអត់ល្អ ចុះតាខ្ញុំគេសម្លាប់បាត់ហើយ ។ ដល់នេះខ្ញុំនៅហ្នឹងទៅ ដល់នៅគេដកបងនេះមួយចេញទៅពីកងតំបន់ទៅមកកាន់សហករណ៍ ។ សហករណ៍ដែលគេហៅភូមិសម្បូរណ៍ ខ្ញុំនោះគេឲ្យមកធ្វើអង្គរក្សប្រធានសហករណ៍ ហើយដកពីទាហាន មកនៅហ្នឹង! នៅទៅមកៗបាន តា វឿន គណៈតំបន់ហៅខ្ញុំមកធ្វើអង្គរក្ស ។ ខ្ញុំត្រលប់ត្រលិនតាកាលហ្នឹង ។

ថនៈ ប៉ុនពីមុនពូនៅតំបន់ តំបន់កងអើ វរៈ! តំបន់៧០៥ពូហ៊ៅ?

សៀនៈ ខ្ញុំនៅនេះ ប៉ុនដល់នោះគេថាខ្ញុំ គេជ្រើសរើសឲ្យតែ៣ទេ យន្តហោះកាលហ្នឹង!

ថនៈ ខាងណាគេជ្រើសរើសពូ?

សៀនៈ ចាំសិនណាលោកគ្រូ! កាលហ្នឹងខាងអង្គការគេឲ្យទៅរៀនបើកយន្តហោះទៅចិន ទៅអី! ក៏ដល់គេស្រាវជ្រាវប្រវត្តិរូបទៅ នៅសល់ខ្ញុំពីរនាក់អារំសាយនោះទៅថាប្រវត្តិរូបអត់ល្អ គេថាយើងអ្នកកសិករថ្នាក់កណ្តាល ហើយប្រវត្តិរូបមានទៅយើងមានឈ្មោះហ្នឹង គេសម្លាប់តា សម្លាប់អីអញ្ចឹង ក៏គេដក ឲ្យនៅដាំបាយជ្រូកនៅមន្ទីរភូបាំង នៅស្រុកសៀមប៉ាងហ្នឹង ។

ថនៈ ចុះពេលមុនវឿនមនកគ្រប់គ្រងហ្នឹង នរណាអ្នកគ្រប់គ្រងមុនគាត់ហ្នឹង?

សៀនៈ មិនស្គាល់ឈ្មោះអីទេ! ឈ្មោះតាប៊ុត គណៈតំបន់ ដល់គេដកចាំមើលណាស៎ វឿន ពីកងពលទី១ភូមិភាគបស្ចឹម! គេដកបងវឿនឲ្យមកកាន់តំបន់១០៨ ជាមួយតាយឿនៗ តែតាយឿនស្លាប់បាត់ហើយ ។

ថនៈ គាត់ឈ្មោះអីវឿន?

សៀនៈ មិនដឹងគាត់ឈ្មោះអីទេ! ឮតែគេហៅវឿនៗ ។

ថនៈ មិនមែន មាស វឿនទេ?

សៀនៈ មិនមែនទេ! ខ្ញុំនៅជាមួយគាត់រហូតដកពីកងពលទី១ ដកតាខេងពីកំពង់សោម ដកតាវឿន ដកនែ៎កតាយឿន ដកមកកាន់តាយឿនហ្នឹងកាន់គណៈតំបន់១០២ ។ តាវឿនហ្នឹង ដកមកកាន់តំបន់១០៨ស្ទឹងត្រែង ។

ថនៈ យឿន១០២?

សៀនៈ ១០២ រតនៈគិរី! ក្រោយមកគេដកមកកាន់នៅ ១០៨ហ្នឹងទាំងអស់គ្នា ទាំងតាវឿន ទាំងតាយឿនៗ តាវឿន មកមុន!

ថនៈ តាវឿន ១០៨?

សៀនៈ បាទ!

ថន៖ ហើយខេង?

សៀន៖ តាខេង នៅភូមិភាគ ។ ស្លាប់ហើយដែរតាខេង ស្លាប់ក្នុងនេះឯងត្រពាំងប្រាសាទ ។

ថន៖ ចុះគណៈតំបន់ចាស់ហ្នឹង តាប៊ុត គេដកគាត់ទៅណាវិញ?

សៀន៖ គេសម្លាប់! ប៉ុន្តែមិនដឹងខាងណាសម្លាប់មិនដឹងទេណា ។ បើមេវរៈ បងថ្លៃខ្ញុំហ្នឹង ខ្ញុំដឹងអ្នកសម្លាប់ អ្នកសម្លាប់នោះតារឿនអ្នកបញ្ជាសម្លាប់ ឈ្មោះ អឿន ។ ហើយបងអឿននោះស្លាប់ដែរហើយ ។

ថន៖ បងពូដែលមានឈ្មោះ ធី ហៅ សា?

សៀន៖ បាទៗ!

ថន៖ មូលហេតុអី បានជាគេចាប់គាត់?

សៀន៖ ខ្ញុំមិនដឹងដែរជំនាន់នោះ ខ្ញុំឃើញគាត់ដឹកនាំល្អៗ កាលនោះគេថាខ្សែសម្លាប់អាមុននោះ គេថាក្បត់ជាមួយគ្រូឯងនេះ ទំនាក់ទំនងគ្នាដូចខ្ញុំធ្លាប់ចាត់តាំង គ្រូឯងមកនេះដូចចោតគត្នា ។

ថន៖ រឿននេះគាត់ជាផង?

សៀន៖ បាទ!

ថន៖ ចុះពូនៅជាមួយកង បងរបស់ពូហ្នឹង ធី ហ្នឹង អត់មាននិយាយថាចាប់គាត់អីអត់មានបញ្ហាអីដល់ពូទេ?

សៀន៖ អត់មានបញ្ហាទេ! នៅក្នុងអង្គភាពនេះអត់មានបញ្ហាទេ ។ ប៉ុនដល់ខ្ញុំចេញ ខ្ញុំចេញមកនៅជាមួយតារឿននោះបាន គេចាប់ពង្រាត់៧៨ហ្នឹង ប្រដាត់ប្រភឹងហ្នឹង គេចាប់គាត់ ។ គេចាប់គាត់មកសម្លាប់ចោលនោះអូរស្វាយយើងហ្នឹង ឃុំអូរស្វាយយើងហ្នឹង ទន្លេមេគង្គ ។

ថន៖ អញ្ចឹង រឿន ហ្នឹង ក្រោយមកទៀតគេចាប់មែនទេពូ?

សៀន៖ រឿន អត់ទេ! ក្រោយមក៧៩ មកកាន់កងពល ។

ថន៖ ពូនិយាយមិញហ្នឹង គេមកចាប់បងរបស់ពូទេ?

សៀន៖ បាទ! អ្នកសម្លាប់ហ្នឹងតារឿនទេ អ្នកបញ្ជាឲ្យទៅចាប់ ទៅចាប់ហ្នឹង ប៉ុនសម្លាប់នៅអូរស្វាយនេះ ។ សព្វថ្ងៃដាក់ឃុំអូរស្វាយ ទន្លេមេគង្គ ។

ថន៖ នៅឆ្នាំប៉ុន្មាន?

សៀន៖ នៅឆ្នាំ៧០ ដើម៧៨ហ្នឹង ។

ថន៖ កាលហ្នឹង ពូនៅជាមួយបងពូ?

សៀន៖ អត់ទេ! កាលហ្នឹង ខ្ញុំឈប់នៅហើយ! ខ្ញុំមកធ្វើនិរសារនៅជុំគ្នា តា វឿនហ្នឹង។ នៅឆ្នាំសចុង ៧៧ ខ្ញុំមកនៅជាមួយតាវឿន មកនៅធ្វើនិរសា កាលហ្នឹងគេហៅអង្គរក្ស។

ថន៖ អញ្ចឹង ដកពូ ដកពី៧០៥ហ្នឹងមកធ្វើនិរសា?

សៀន៖ មុនដំបូងខ្ញុំមកនៅព្រំដែន ដកពីព្រំដែនលាវមក ខ្ញុំ មកនៅឯខិនេះ ខិចាវគោក ចាវទឹកនេះ ភូមិខិយើង គេហៅភូមិខិ ពួកខ្មែរយើងនៅហ្នឹង។

ថន៖ ភូមិខិ!

សៀន៖ ដល់នេះគេដកខ្ញុំ ទៅបើកយន្តហោះ នៅពេលដែលទៅបើយន្តហោះ គេថាប្រវត្តិរូបអត់ល្អ ខ្ញុំមកនៅអាមន្ទីរភូបាំងណា ពីរនាក់អាសាយហ្នឹង។

ថន៖ ហើយបានចេញពីហ្នឹងមក?

សៀន៖ ចេញពីហ្នឹង ខ្ញុំមកនៅនិរសាប្រធានសហករណ៍! ប្រធានសហករណ៍ នោះគេដកពីអង្គភាពហ្នឹង ដែរ ប្រធានភូមិរាល់ថ្ងៃហ្នឹង។

ថន៖ ចេញពីភូបាំង មកធ្វើនិរសារបស់ប្រធានភូមិ?

សៀន៖ បាទ!

ថន៖ កាលនោះសហករណ៍អីវិញពូ?

សៀន៖ សហករណ៍ភូមិសម្បូរណ៍។

ថន៖ នរណាប្រធានសហករណ៍?

សៀន៖ ដល់នេះខ្ញុំអត់បាននៅជាមួយទៀត ចៅហ្វាយស្រុកគេចង់បានខ្ញុំ ខ្ញុំមកនៅជាមួយចៅហ្វាយ ស្រុកទៀត។ នៅអត់បាន១ខែទេជាមួយសហករណ៍ គាត់ស្រលាញ់ខ្ញុំ គាត់ហៅខ្ញុំមកនៅ ជាមួយតាយ៉ង់នេះ ចៅហ្វាយស្រុកសៀមប៉ាង។

ថន៖ ពូមកនៅជាមួយតាយ៉ង?

សៀន៖ បាទ!

ថន៖ ហើយបានរយៈពេលយូរទេ?

សៀន៖ នៅបាន១ខែ អភិបាលរងហ្នឹង រងពីតាយ៉ង់ គាត់មកយកខ្ញុំមកនៅទៀត មកនៅធ្វើនិរសាខ្ញុំ ទៀត ឈ្មោះ តាខាំជិ។

ថន៖ គាត់ជនជាតិ?

សៀន៖ គាត់ជនជាតិ គាត់ឈ្មោះតាខាំជិ អភិបាលរង។

ថន៖ ម៉េចបានគេដកពូ? គេចូលចិត្ត?

សៀនៈ មិនដឹងទេ! ម៉េចីមិនដកបើនៅជាមួយគេប្រហែលជា២ខែមក បានអាវៀនគណៈតំបន់ គាត់ឃើញខ្ញុំ គាត់សុំពីតានោះរហូត រហូតដល់សព្វថ្ងៃនោះ ទើបតែចេញបាន៣ ទៅ៤,៥ឆ្នាំ ។

ថនៈ ពូ! ពេលតាវៀន បញ្ជាឲ្យចាប់ពូសាហ្នឹង ពូនៅជាមួយគាត់ទេពេលហ្នឹង?

សៀនៈ បាទ! នៅហ្នឹង ។

ថនៈ ពូ! ដឹងទេ?

សៀនៈ ដឹង! ប៉ុន្តែមិនដឹងជារឿងអី គ្រាន់តែថាគេអត់ឲ្យខ្ញុំទៅសម្លាប់ទេ ព្រោះគេឲ្យខ្ញុំចាំឡាន ។ ខ្ញុំអ៊ីខ្ញុំ! គេសម្លាប់ ប៉ុនអ៊ីខ្ញុំគេបាន ឃើញហ្នឹងភ្នែករបស់ខ្ញុំ អ៊ីឈ្មោះ អ៊ីជង់! កាលនោះគាត់ធ្វើឃុំ ហ្នឹងតាវៀនដែរ! គាត់ឲ្យសម្លាប់ ។

ថនៈ មេឃុំអីគេ?

សៀនៈ មេឃុំសន្តិភាព ឈ្មោះ អ៊ីជង់ សម្លាប់ដែរ ។

ថនៈ ហ្នឹងពូបានឃើញ ផ្ទាល់ភ្នែក?

សៀនៈ ផ្ទាល់ភ្នែក!

ថនៈ ដូចថាគាត់ដឹងជាបងប្អូនពូ និយាយថាក្នុងហេតុការហ្នឹងម៉េចដែរពេលហ្នឹងពូ?

សៀនៈ អារម្មណ៍រន្ធត់ចិត្ត ខ្លាចតែគេយកទៅដែរនោះ ព្រោះគេដឹងជាសាច់ញាតិអ៊ីខ្ញុំ គេចាប់មក ប៉ុន្តែគេអ្នកចាប់ ឈ្មោះតាឡាយទេ អ្នកចាប់មក ។ ដល់យប់នោះខ្ញុំទៅមើលទៅឃើញអ៊ីខ្ញុនឯងបង្កើត ហើយមានឈ្លបបីនាក់ទៀត ប៉ុនអត់ស្គាល់ឈ្មោះទេ! ក្មេងៗអានោះមួយលោតពី លើឡានដាច់ខ្សែអង្រឹងទៅ គេបាញ់ផាប់ អាឆុន គេចាញ់ផាប់ ។ បើអ៊ីខ្ញុំគាត់អត់ហ៊ានលោតទេ ។ បាញ់សម្លាប់ បើក្រៅពីនោះគេដឹងទៅទន្លេ មិនដឹងថាយកទៅសម្លាប់ឯណាទេ ខ្ញុំដឹងថាអ៊ីខ្ញុំគេសម្លាប់នៅក្បែរ ។

ថនៈ ម៉េចបានគេចាប់ពូ?

សៀនៈ កាលហ្នឹង គេចោទ គេថាយើង ហៅខ្សែសេ-អ៊ី-អា ខ្សែ អាមេរិចខ្សែអី ថាក្បត់អង្គការថាក្បត់អី គាត់សួរចម្លើយថាគាត់ អត់ក្បត់ ហើយក៏គាត់អត់ដឹងសេ-អ៊ី-អាថាម៉េចផងគាត់អត់ស្គាល់ គាត់មានតែខំឲ្យប្រជាជនធ្វើស្រែ ធ្វើចម្ការ(ស្តាប់ពុំបាន) ខ្ញុំឆ្លើយតែប៉ុណ្ណឹង ។ អត់មានថាគាត់មានខ្សែ មកពីអាមេរិច មកពីអីណាក៏អត់ ។

ថនៈ ពីមុនគាត់ធ្វើអី ឈ្មោះដូហ្នឹ?

សៀនៈ ធ្វើមេឃុំ!

ថនៈ មេឃុំចាស់?

សៀនៈ ជំនាន់ខ្មែរក្រហមហ្នឹងណា ។

ថនៈ ប៉ុន្តែពីមុនគាត់ទៀត?

សៀនៈ ពីមុនគាត់ ប្រជាជនធម្មតា ។

ថនៈ ចុះពីមុន ពូបានចាប់ហ្នឹង ពូបាននិយាយជាមួយគាត់ទេ?

សៀនៈ អត់ហាននិយាយទេ ម៉េចហាននិយាយបើគេនៅជិតហ្នឹង ពួកខ្លាំងដូចគាត់អញ្ជឹង ម៉េចហ៊ាននិយាយបើ ចង់និយាយដែលតែម៉េចហ៊ាន បើខ្លាចគេដឹង បើគេដឹងរឿងហើយ ជាក្អួយជាអីរបស់គាត់ដែរ ហើយខ្ញុំនៅជាមួយគារឿនហ្នឹង គេប្រុងដកខ្ញុំ ទុកកងចល័ត ព្រោះគេដឹងថាខ្មែរខ្ញុំអត់ល្អ មានខ្មែរស្រឡាយត្រូវប៉ះគ្នា អ្នកសម្លាប់អញ្ចឹងណា ។ ប៉ុនចជន្យអី ៧៨ហ្នឹង រត់ទៅរួចខ្លួនខ្ញុំ កាលនោះខ្ញុំប្រុងរត់ទៅអន្លុភាពវិញ ទៅតាហានវិញណា ខ្ញុំថាបើសិនដកខ្ញុំទៅកងចល័ត ខ្ញុំអត់ទៅទេ ខ្ញុំសុខចិត្ត វាយយួនហ្នឹងនៅសមរភូមិវិញ ស្លាប់ៗនៅសមរភូមិវិញ លើកលែងគេចេះទៅថានៅកងចល័ត យកខ្ញុំទៅវាយចោល នេះបារម្ភភ័យដែរ ។

ថនៈ ពូអត់ហ៊ាន! អត់ហាននៅកងចល័ត សុខចិត្ត?

សៀនៈ ខ្ញុំថាទោះបីខ្ញុំយ៉ាងម៉េច ខ្ញុំមិនទៅទេកងចល័ត ខ្ញុំទៅអន្លុភាពខ្ញុំវិញ ខ្ញុំសុខចិត្តថាទៅវាយយួនទៅណា បើស្លាប់ក៏ស្លាប់ដើម្បីជាតិ អាក្នុងខែហ្នឹងល្មមប្រទ្រួសប្រត្រាយយួនចូលស្រុកហ្នឹង នៅជាមួយគាត់រហូត ។

ថនៈ ចុះកាលហ្នឹងចាប់! ក្រៅពីចាប់អ៊ី របស់អ៊ីឈ្មោះហ្នឹង ហើយវាឈ្មោះអី? ឈ្មោះសាហ្នឹងមានចាប់អីអ្នកផ្សេងៗទៀតទេ ឬច្រើនជាងហ្នឹង?

សៀនៈ អត់! អត់! មានចាប់ទៀទេ ព្រោះយើងរត់ហើយ ។

ថនៈ បើនិយាយថាពេលចាប់អ៊ីរបស់ពូហ្នឹងមានចាប់អ្នកផ្សេងៗទៀតទេ?

សៀនៈ ចាប់! ប៉ុនគ្រាន់តែ ខ្ញុំអត់ស្គាល់ ចាប់ពួកឈ្លបណ៎ា ។

ថនៈ ចាប់ថ្នាក់លើៗដែរពូ? ខាងស្រុក ខាងអីមានចាប់ទេ?

សៀនៈ ខាងស្រុក ចាប់ តាយ៉ន់ ចាប់ ដុំអីវាយចោលអស់ហើយ ។

ថនៈ តាយ៉ន់ តាជុំគេចាប់ដែរ?

សៀនៈ កាលហ្នឹង មិនដឹងខាងណាទេ គេអ្នកចាប់ ។ ចាប់វាយអ្នកក្រោយៗមក ដូចថាតា ខាំជិខ្ញុំនៅយូរហើយ គេវាយចោលអស់ហើយ ដូចនែ៎ក បងសា ចៅហ្វាយស្រុកនេះក៏គេសម្លាប់នែ៎កាខាំជិ នោះក៏គេសម្លាប់ ក្រោយហើយខ្ញុំចេញហើយចេញផុតហើយ ប៉ុន្តែគេសម្លាប់ទាំង

អស់ អត់មាននៅទេ ។ ដល់ចៅហ្វាយស្រុកនេះឡើងថ្មី តាជា តាជុំនោះក៏គេសម្លាប់ដែរ ។ សុទ្ធតែឡើងចៅហ្វាយស្រុកថ្មី ។

ថនៈ  ប៉ុនពូដែលថាទៅផ្ទាល់ជាមួយឈ្លបនោះ ពូទៅផ្ទាល់ថាទៅចាប់នោះ ពូមានតែប៉ុន្មាននាក់កាលហ្នឹង?

សៀនៈ ពួកទៅចាប់?

ថនៈ  ពួកទៅចាប់ មានប៉ុន្មាននាក់កាលហ្នឹង?

សៀនៈ ពួកឈ្លបហ្នឹង?

ថនៈ  បាទ! មានជួបអ្នកផ្សេងទេ?

សៀនៈ មាន៣ ទៅ៤នាក់នោះ ប៉ុនអ្នកដែលគេចាប់នោះតែ២ ឬ៣នាក់ទេ ប៉ុនខ្ញុំអត់ស្គាល់ឈ្មោះទេ ។ ខ្ញុំមកដល់ឃើញ អីនៅក្នុងឡាន គេបំបែក គេដឹកទៅឡានផ្សេងណា ។ គេយកអីខ្ញុំទៅសម្លាប់មួយ ក្រៅពីហ្នឹងគេយកឡាណា ដឹកយកទៅទន្លេ ។

ថនៈ  សម្លាប់នៅអូរស្វាយហ្នឹងហ៎?

សៀនៈ អត់ទេ! អីខ្ញុំសម្លាប់នៅអូរនេាង ។

ថនៈ  អូរនេាង ស្រុកសៀមប៉ាង ។ ពេលគេចាប់មកមានសួរចម្លើយទេ?

សៀនៈ សួរចម្លើយតា!

ថនៈ  សួរនៅណា?

សៀនៈ សួរនៅកន្លែងដែលសម្លាប់នោះ គេវាយ គេចាក់មួយចំពុះទន់ ។

ថនៈ  អូរនេាង អាកន្លែងហ្នឹងជាឃុំ មិនមែនជាមន្ទីរសន្តិសុខដែរ ឬយ៉ាងម៉េច?

សៀនៈ អត់ទេ! ព្រៃយើងធម្មតាទេ មិនមែនជាសន្តិសុខទេ! សន្តិសុខនៅស្ទឹងត្រែងនៅអូរពងមាន់នេះទេ ។ កាលហ្នឹងទៅវាង ទៅវាងគ្រប់គ្រងធំនៅខេត្តហ្នឹងតែម្តង នៅភូមិភាគហ្នឹង ចាប់ពីរតនៈគិរី, មណ្ឌលគិរីស្ទឹងត្រែង ពីណាមក យកមកដាក់នៅអូរពងមាន់ទាំងអស់ ។

ថនៈ  អាអូរកន្លែងអីហ្នឹង?

សៀនៈ បាទ! អញ្ចឹង អូរនេាងហ្នឹង នៅក្នុងនេះទេ ក្នុងស្រុកសៀមប៉ាងទេ អញ្ចឹងអ្នកដែរចាប់មកពីក្នុងស្រុកហ្នឹង គឺយកមកពីអូរនេាងទាំងអស់ ឬក៏យកចាប់មកសម្លាប់អារត់អាវាយ បានមកដល់ស្ទឹងត្រែងនេះ ។ គេសម្លាប់ចោលទៅតាមព្រៃចេះៗ អត់មានសន្តិសុខទេ សម្លាប់ដូចថាសម្លាប់ចោល តាមព្រៃ តាមអីហ្នឹង ។

ថនៈ ហ្នឹងនិយាយថាបញ្ហាចាប់ហ្នឹង បញ្ហាពីថ្នាក់លើពីតា វឿន ហ្នឹងទៀត ឬក៏?

សៀនៈ ពីតាវឿន! ពីព្រោះខ្ញុំនៅជាមួយគាត់ ដឹងតែត្រឹមគាត់តាមមើល ។

ថនៈ បន្ទាប់ពីតាវឿនមក ខាងក្រោមៗគាត់ពីណាទៀត នៅតំបន់១០៤ ។

សៀនៈ តំបន់១០៤ ក្រោយមក?

ថនៈ បន្ទាប់ពីគាត់ណា បន្ទាប់ពីគាត់គណៈតំបន់ ខាងក្រោមគាត់ ?

សៀនៈ មានតាយឿង នៅកាន់១០២មុននោះ ។ គាត់ស្លាប់ហើយ តាយឿងនោះ ។

ថនៈ ហ្នឹង អានុរបស់ពួកគាត់ណា?

សៀនៈ របស់តាវឿន ។

ថនៈ តាវឿនហ៎ ។ ហើយ តា យឿងហើយពីណាទៀត?

សៀនៈ មានតែប៉ុណ្ណឹងឯង អាហ្នឹងប្រធានមន្ទីរ ប្រធានមន្ទីរតាណាត ប៉ុន្តែតាណាត គាត់មិនធ្វើអីទេ គាត់ស្លូតណាស់ តាណាតនៅអន្លង់វែងហ្នឹង ។ តាណាត គាត់មិនដឹងរឿងទេ តា? តាណាត គេយកទៅសម្លាប់ឯណាឯណី គាត់មិនដឹងសោះ ។

ថនៈ បញ្ហា បញ្ហាទៅ តាវឿន?

សៀនៈ បាទ! ដឹងៗ ត្រឹមតែពួកនិរសាទេ ដូចពួកខ្ញុំណាស់ ដឹងតែប៉ុណ្ណឹងព្រោះថា ខ្សែខាងណាខាងណី អត់ដឹងគ្រាន់តែដឹងអ្នកជិតៗបានដឹង ។ អាហ្នឹងអត់ចូលសន្តិសុខទេអញ្ចឹង ។ សម្ងាប់ពាសវាល ពាសកាល ដូចថាអត់មានចូលដល់សន្តិសុខអាកន្លែង រវាំងកន្លែងអី អត់បានចូលទេ ព្រោះនៅ ស៊ីងគ្រែងរវាំងហើយ ព្រោះកន្លែងធំគេ ខាងសន្តិសុខ ខាងអូរពងមាន់ ។ ទាំងគេទាំងខ្ញុំ ឲ្យទេ ឃើញឡាន រត់ទៅវាលហ្នឹងឃើញខ្លាចគ្រប់តែគ្នា ។

ថនៈ ខ្លាចៗយ៉ាងម៉េចពូ បើពូនិរសា គាត់ផ្ទាល់អញ្ចឹង?

សៀនៈ ទោះបីអ្នកធំ ក៏ខ្លាចដែរឲ្យតែឃើញឡាននោះ ចេះតែខ្លាចរៀងៗខ្លួន ។

ថនៈ ចុះពូនៅជាមួយគាត់ ផ្ទាល់អី?

សៀនៈ តាវៀងនោះ មិនមែននៅជាមួយគាត់ផ្ទាល់ណានៅជាមួយ កន្លែងភូមិភាគ ។

ថនៈ តាវៀង?

សៀនៈ បាទ! តាវៀង គាត់ប្រធានសន្តិសុខនៅខេត្តស៊ីងគ្រែង ប៉ុនស្លាប់ដែរហើយ តាខាំវៀង ។

ថនៈ អញ្ចឹង តាវឿងហ្នឹងថាឲ្យចាប់ហ្នឹង មានតាសេ តាអីដែលពូ ព្រោះដូចថាតាសេទៅជាឲ្យអ្នក ដែរ?

សៀនៈ អត់ទេ! សួរយើងធម្មតា សួរវាយៗទៅណា អត់មានកត់អត់មានអីទេណា ។

ថនៈ គាត់អ្នកសួរផ្ទាល់ ឬយ៉ាងម៉េច?

សៀនៈ គាត់ សួរផ្ទាល់! វាយផ្ទាល់! វាយហ្នឹងរំពាត់មានឃើញថាគាត់ផង សួរចម្លើយធម្មតា ។

ថនៈ ហើយពេលទៅចាប់ហ្នឹង គាត់បញ្ជាឲ្យទៅចាប់ ឬយ៉ាងម៉េច?

សៀនៈ បញ្ជាឲ្យទៅចាប់ បញ្ជាដូចថាហៅមកធ្វើការដូចថា ខ្ញុំមានមុខងារដូចជាឈ្លប ដូចថាប្រធានភូមិឧទាហរណ៍ណា អញ្ចឹងហៅធ្វើការមក ហៅឲ្យមកឡើងឡាន ឡើងឡានមក ផុតពីភូមិមួយ គឺឡូចាប់តាមផ្លូវ

ថនៈ គាត់ទៅហៅផ្ទាល់ ឬមួយក៏យ៉ាងម៉េច?

សៀនៈ ឲ្យអ្នកភូមិហៅ ប៉ុន្តែខ្ញុំវាមិនដឹង មិនដឹងថាគេហៅរបៀបៗម៉េចៗអី! មិនដឹងរឿងអីៗ ប៉ុនឡើងមកជិះឡាន ដល់គេចាប់ រឿងអីបានជាគេចាប់ គេមិនប្រាប់យើងណា៎ ដូចខ្ញុំនៅជាមួយណា ។ ដល់ពេលគេចាប់លើឡានព្រោងព្រាត រំមុខអីអញ្ចឹងទៅ ទៅព្រៃ ទៅវាយសួរចម្លើយ ហើយឆ្លល់ ចេះតែឆ្លល់ ។

ថនៈ ប៉ុន្មាននាក់ ដែលទៅនោះ?

សៀនៈ តែ២នាក់ ៣នាក់ហ្នឹង មានច្រើនឯណា! ពួកខ្ញុំប៉ុន្មាន ប៉ុន្តែខ្ញុំ គេពុំសូវឲ្យទៅទេ ព្រោះខ្ញុំនៅក្មេងជាងគេ ទៅតែពួកចាស់ៗ ពួករាងដៃដល់ៗ ។

ថនៈ ទៅឡានមួយហ៎ពូ?

សៀនៈ អា ឡានឡូឡង់គ្រីសស័រ! ស៊ីបពីណស ឡានថ្នាក់តំបន់មានតែអាស៊ីប តែប៉ុណ្ណឹងឯង ។

ថនៈ កាលហ្នឹង អ្នកដែលត្រូវចាប់នោះ ពូមាននៅចាំឈ្មោះទេ?

សៀនៈ ចាំតា! ងាប់អស់ហើយ! នៅរស់តែខ្ញុំ២នាក់ ។ ១នៅកងពលលេខ៨ ស័ក្ត៥ ។

ថនៈ ឈ្មោះអីវិញ?

សៀនៈ ឆុន! នេះផ្ទះវានៅនេះ ។

ថនៈ ស្អី ឆុនពូ?

សៀនៈ ស្អី ឆុនទេ ក្លេចឈ្មោះ ត្រកូលវា ប៉ុនវានៅក្មេងដូចខ្ញុំ ។ វាអត់អ្នកសម្លាប់អីទេ គ្រាន់តែដឹងដូចតែខ្ញុំដែរ ។

ថនៈ មិនមែនអ្នកចាប់អ្នកអីទេ?

សៀនៈ បាទ! បើអ្នកសម្លាប់មានបងឡាយ មានអឿន, ប៉ុនស្លាប់អស់ហើយ ។ ស្លាប់ហ្នឹងត្រូវគ្រាប់ ។

ថនៈ ឆុនហ្នឹង គាត់គ្រាន់តែទៅជាមួយចាប់ទេហ៎?

សៀនៈ បាទ! គ្រាន់តែឃើញដូចខ្ញុំដែរ ស័ក្ត៥ នៅវរៈ៨ ។

ថនៈ ចុះទៅហ្នឹង មានទេចាប់ មានតាវឿន ហ្នឹងគាត់ទៅដែរ ទៅជាមួយគ្នាទាំងអស់ហ្នឹង?

សៀនៈ អត់ទេ! គាត់ហៅមកជិះឡានជាមួយគ្នាអ្នកទោសហ្នឹង! យើងមិនដឹងវាអ្នកទោស អ្នកទោសនោះ ស្រាប់តែចូលដល់ព្រៃនោះ ចាប់នៅលើឡាន ។ អ្នកដឹង គ្រាន់តែដឹងដូចខ្ញុំ អង្គរក្សគេដែរ តែពុំដឹងរឿងអីគេសោះ ស្រាប់តែគេចាប់ព្រួសប្រាស់ បេះតែឆ្វល់ ។

ថនៈ ប៉ុន្តែ! ចង់ ខ្ញុំចង់សួរពូពេលដែរទៅហៅអ្នកហ្នឹងមកចាប់ហ្នឹង តាវឿនហ្នឹងទៅឡានជាមួយគ្នាតែម្តង ។

សៀនៈ អាហ្នឹង! សហករណ៍គេអ្នកទៅហៅ សហករណ៍នោះគេទៅហៅមេភូមិ! ឲ្យទៅជួបកន្លែងធ្វើការគណៈតំបន់នោះ នេះមកទៅគ្នាអត់ដឹងរឿង! មកនេះថាទេរៀន ទៅរៀនសូត្រទៅអីស្រុកឡើងឡានទៅ ជាមួយគ្នាហ្នឹង!

ថនៈ ឡើងឡានហ្នឹងតាវឿន គាត់នៅហ្នឹងទេ?

សៀនៈ នៅហ្នឹង!

ថនៈ នៅឡានជាមួយគ្នា!

សៀនៈ បាទ! នៅឡានជាមួយគ្នា ។ ដល់ពីភូមិគេ ចាប់កណ្តាលផ្លូវ វាយចោលតាមផ្លូវនោះទៅ ។ អាហ្នឹងថាមិនមែនសន្តិសុខធំទេ សន្តិសុខយើង សន្តិសុខធំវាបោះតែអាហ្នឹងគេសម្លាប់នៅអូរពងមាន់ ។

ថនៈ ពូនៅជាមួយតាវឿនហ្នឹងនិរសារគាត់ហ្នឹង! និរសាហ្នឹងមានតែទៅតាមគាត់?

សៀនៈ តាមគាត់យាម ទាំងយប់ទាំងថ្ងៃ បានអីទេយាម ។ គ្នាប៉ុន្មាននាក់ ៣ ទៅ៤នាក់ ពេទ្យ១នាក់ ។ មានខ្ញុំ, មានឆុន, មានឡាយ, មានអឿន, អឿនមានឈ្មោះពីរអឿន អឿនស អឿនខ្មៅ ។

ថនៈ អឿនស អឿនខ្មៅ!

សៀនៈ អឿនសនៅសព្វថ្ងៃ នៅអន្លង់វែង! អឿនខ្មៅស្លាប់បាត់ហើយ ។ បងឡាយ បងឡាយស្លាប់ហើយ ។ អាលាង ក៏ស្លាប់ដែរអាលាង ។

ថនៈ ចុះមន្ទីរសន្តិសុខ តំបន់១០៤ នៅកន្លែងណាអ៊ី?

សៀនៈ អត់មាន! មានតែកន្លែងតាវៀងហ្នឹង ។

ថនៈ មានអីគេហៅសន្តិសុខ?

សៀនៈ បាទ! បើសិនអ៊ំ គេចាប់មកទាំងឡាន ទាំងកាណូតៗគឺតាវៀង គាត់ដើរចាប់ គាត់មកហ្នឹង បើថាកន្លែងតំបន់នោះអត់មានទេ វាដូចខ្ញុំថាអញ្ចឹង វាចាប់មួយ ពីរបេះចឹង អាហ្នឹងគេសម្លាប់

តាមព្រៃណា ប៉ុនមានអ្នកទោសខ្លះដែរ ដែលរត់រួចពីចម្ការកៅស៊ូ ជប់មេមត់ ពីក្រចេះអីគេមក ។ រត់មកទាំងស្រីទាំងប្រុសនោះ មកនៅកន្លែងខ្ញុំ វាជិតច្រើនរស់ ។

ថន: អ៊ឺ មានអ្នកទោសដែលរត់ទៅហ្នឹងដែរ?

សៀន: ដូចថាពួកសហជីព ពួកកម្មករអី នៅចម្ការកៅស៊ូណារត់មក មានកង់មានអី រត់មកគេចាប់ដាក់កន្លែងខ្ញុំហ្នឹង យកទៅដាក់ដេកនៅក្នុងផ្ទះរោងប៉ុណ្ណឹងៗ ដេក៣,៤ ទៅ៥នាក់ហ្នឹង ។ ស្រីផងប្រុសផងខាងព្រះវិហាររត់ រត់ទៅចាប់ គេចាប់ដាក់កន្លែងខ្ញុំហ្នឹង រស់វិញ អាហ្នឹងគេប្រគល់មកខេត្ត ។ អត់សម្លាប់ទេ គ្រាន់តែគេសួរចម្លើយថាមកពីណា មកពីណាទេ ថារត់ពីចម្ការកៅស៊ូពីមេមត់ ក្រែកកំពង់ចាម ប៉ុនអាហ្នឹងគេអត់សម្លាប់ទេ ។

ថន: ប៉ុន្តែ ពូដឹងថាពេលនៅកន្លែងពូ ពេលដែលបញ្ជូនចេញមក ក្រោយមកម៉េចបានដឹងថាសម្លាប់?

សៀន: អត់ដឹង ពេលនោះ យើងដូចថាបញ្ជូនមកសម្លាប់ បញ្ជូនមកខេត្តគេវិញណា ។ សួរថាស្រុកកំណើតនៅឯណា ថានៅព្រះវិហារ នៅកំពង់ចាមនេះ បញ្ជូនទៅវិញ ប៉ុននេះដែលចេញពីដែលខ្ញុំអត់ស្លាប់ បានគេចេញពីខ្ញុំ ខ្ញុំវាអត់ដឹង បាទ! អត់ដឹងទេ ប៉ុនដឹងថាអត់ស្លាប់នៅកន្លែងខ្ញុំ ខ្ញុំលួចឲ្យបាយឲ្យអី ខ្ញុំយាម ឲ្យបាយហូបចេះៗអីៗ ពួកអ្នកទោស ។

ថន: ចាប់មកឃុំ ឃុំនៅកន្លែងណាពូ? កន្លែងអាមន្ទីរតំបន់តែម្តង ឬក៏?

សៀន: មន្ទីរតំបន់នៅជិត កន្លែងមន្ទីរតំបន់ហ្នឹង គេហៅមន្ទីរក្រោម ក្រុមស៊ីងត្រែង ។

ថន: នៅម្តុំណាផ្លូវលោកពូ?

សៀន: ផ្លូវហ្នឹងគេ ពីមុនវាមន្ទីរគេទើបតែធ្វើថ្មីទេ មន្ទីរប៉ុនផ្លូវគេឈប់នៅហើយ គេភូមិប្រជាជនគាត់មកនៅវិញណា ផ្ទះហ្នឹងកាលជំនាន់៣ឆ្នាំ ជំនាន់ខ្មែរក្រហម ផ្ទះហ្នឹងមួយជួរហ្នឹងគេជំលៀសអស់ម្ចាស់គេណាស់ ពួកខ្ញុំចេញពីមន្ទីរលើមក មកនៅឯក្រោម ទើបតែមកនៅ ទើបបានប៉ុន្មានខែយួនចូលស្រុក ។ ខាងក្រោមមកនេះកំពង់ដែស៊ីងត្រែងហ្នឹង ។

ថន: អញ្ចឹងពូនៅអ៎ នៅមន្ទីរ តំបន់ហ្នឹងអ៎ ការងារពូថាយាមការពារតាវឿនហ្នឹងទេ?

សៀន: បាទ!

ថន: តាវឿនហ្នឹង គាត់ស្នាក់នៅមន្ទីរតំបន់ហ្នឹង?

សៀន: បាទ! គាត់នៅតំបន់ហ្នឹង គាត់ដាប់ៗតាមស្រុក ចុះទៅតាមស្រុកហ្នឹង គាត់ថាស្អែកហ្នឹង គាត់ចុះទៅស្រុកសៀមប៉ាង នៅស្រុកសៀមបូក ។

ថន: គាត់ចុះហ្នឹង គាត់ចុះទៅចាប់ ឬមួយ?

សៀនៈ គាត់ចុះទៅពង្រឹងសហករណ៍ ពីបញ្ហាធ្វើស្រែ ធ្វើចម្ការ ឮគាត់ប្រកាស តាមមេក្រុតាម គាត់ជុំប្រជាជន៣, ៤ ទៅ១០, ២០នាក់ ប្រធានៗសហករណ៍ៗ គាត់និយាយរឿងធ្វើស្រែ១ហិកតា៣តោននេះប្រឹងប្រែងការងារតែប៉ុណ្ណឹងឯង ។

ថនៈ អញ្ចឹងពូ ឲ្យតែគាត់ទៅ ទៅជាមួយដែរត្រូវទេ?

សៀនៈ ទៅ!

ថនៈ ទៅប៉ុន្មាននាក់ក្នុងមួយកង?

សៀនៈ ពួកខ្ញុំឡានវា៣គ្រឿង! ឡានគាត់កណ្ដាល ឡាននិសារមុខក្រោយ ពេទ្យ ទាំងអ្នកដាំបាយ ។

ថនៈ ទាំងអស់ ប៉ុន្មាននាក់ពូ?

សៀនៈ បើទាំងស្រីផង ១២នាក់ ។ គ្រាន់តែខ្ញុំមិនដឹងប្រវត្តិគាត់វាយ៉ាងម៉េច យ៉ាងម៉ា វាមិនដែរដឹង ។ ដល់ពេលគេចាប់ គេចង ខ្ញុំវាមិនដឹងវា វាមនដឹងថាមិនដឹងជារឿងអីៗ ដែលគេចាប់ត្រូវមកសម្លាប់ដូចអ៊ីខ្ញុំនេះឯងណា ។ វាមិនដឹងថា គេប្រាប់នែក យើងមកប្រុងតែចាប់ឈ្មោះ ក ឈ្មោះ ខ ហ្នឹង ខ្ញុំអត់ដឹង អត់ដឹង បើអាចដឹងគឺដឹងតែបងគាត់ចាស់ៗ ជាងខ្ញុំដែរកេទុកចិត្តណា ។ ខ្ញុំដឹង នៅពេលដែលគេចាប់នៅលើឡានតាមផ្លូវនេះ ។ ខ្ញុំដឹងតែប៉ុណ្ណឹងឯង បើអារឿងគេប្រាប់ជាថាទៅចាប់ចះ ទៅចាប់ចុះនៅភូមិនេះ ភូមិនោះ ឈ្មោះចេះ ខ្ញុំអត់ដឹងទេ អត់ដឹងរលីង គេមិន ឲ្យដឹង ខ្ញុំដឹងតែតាមផ្លូវ ដឹងតែពេលគេចាប់រត់ប្រដាត់ប្រភឹង ។

ថនៈ ពេលចាប់ក៏ទៅឡានបីដែរ?

សៀនៈ ឡាន៣ដែរ ។ បើចាប់នោះអ្នកស្រុកគេទៅហៅមក ប្រធានភូមិគេទៅហៅមក បើថាភ្ជួន់ប្រជាជនហើយ ចេញមកចេះ ដូចថាយើងចេញមកខេត្តវិញណា ចេញមកខេត្តគេហៅមនុស្សដែលត្រូវចាប់មកជាមួយយើងមកឡើងឡាន ឡើងឡានជាមួយយើងមកគេចាប់តាមផ្លូវ ។

ថនៈ ឡានហ្នឹង និយាយថាឡាន៣ ហើយមាននិសារនៅខាងមុខ?

សៀនៈ បាទ! និសារនៅចាំ ។

ថនៈ បាទ! និរសារ ហើយឡានគាត់កណ្ដាល?

សៀនៈ ឡានគាត់កណ្ដាល ។

ថនៈ កណ្ដាលនោះគាត់ជិះតែម្នាក់ឯងឬក៏ ?

សៀនៈ គាត់ជិហនែក៎ អង្គរក្សពីរនាក់ទៅ ហើយអ្នកបើកម្នាក់ ។

ថនៈ ហើយឡានខាងក្រោយឡានអ្នកអ៎!

សៀនៈ ឡានខាងក្រោយ ឡានអ្នកដាំបាយ ខាងមុខឡានអង្គរក្ស និរសារ ។

ថនៈ ចាប់យកមកជិះឡានខាងមុខទេ ឬក៏ជិះឡានគាត់?

សៀនៈ ជិះឡានអង្គរក្ស ។

ថនៈ ជិះឡានខាងមុខហ្នឹង ខាងនិរសារ? ពូ ជិះឡានណាវិញ?

សៀនៈ ខ្ញុំជិះជាមួយគាត់ហ្នឹងឯង វាចេះទៀត បើដឹងថាចាប់ចេះ គេធ្វើឡានខូច ធ្វើឡានខូច ហើយចុះរុញឡាននោះ គេចាប់មនុស្សបាត់ ។ ឆ្ងល់ទាំង ខ្ញុំអត់ដឹងខ្ញុំឆ្ងល់ ឆ្ងល់ថាហេតុអ្វីបានចាប់ គេមិនឲ្យយើងដឹង ។

ថនៈ ធ្វើខូចហ្នឹង យើងឈប់ទាំងអស់គ្នា?

សៀនៈ ឈប់ឡាន រុញទាំងអស់គ្នា! រុញអត់ឆេះៗ មិនអ្នកទោសចុះរុញដែរ មកចាប់ ចុះរុញហ្នឹងចាប់គ្រប់ ។

ថនៈ ចាប់តែម្ដង ឬក៏ចងស្លាបសេក?

សៀនៈ ចងស្លាបសេក ហើយរុំភ្នែកកញ្ចឹង ដឹកចូលព្រៃ ។ គាត់សួរចម្លើយ គ្មានឯកសារគ្មានបិចទេ អាហ្នឹងនោះ ។

ថនៈ អញ្ចឹងមានស្រែកមានអីទេកាលដែរចាប់?

សៀនៈ អត់មានស្រែកទេ! ដូចអីខ្ញុំអត់មានស្រែកទេ ។ ហ៊ូបើបងឡាយនេះអាក្រក់ណាស់ បើកហើយប្រាស់ហើយកាប់ទៀត ។

ថនៈ ប្រាស់ហ្នឹង កាប់ទៀត?

សៀនៈ បាទ! កាប់ទាំងរស់! អត់ស្លាប់ទេណា គាត់នៅកំពង់ឆ្នាំង នៅប្រពន្ធគាត់ហ្នឹង ប្រពន្ធហ្នឹងយកប្ដីទៀត ។ ប៉ុនអ្នកសម្លាប់គេ អត់រស់ទេ! ស្លាប់អស់ហើយ ។ តាវឿនហ្នឹងលែងកើតជាមនុស្សម្នាហើយ គាត់ចេញពីគណៈតំបន់តំ៧៩នោះ ប្រធានកងពលកងពល៨៥ ។

ថនៈ កងពល៨៥?

សៀនៈ បាទ! នៅអន្លង់វែងជាមួយខ្មោចតាតេម តាមតេមអនុ តាវឿន ប្រធាន ក្នុងកងពលលេខ៥ មាស មុត នេះឯង ដើរជាមួយតាមុត ។ តាមុត ប្រធានរួម តាវឿន បន្ទាប់ហ្នឹង តាតេម ។ ដល់ឥលូវនេះគាត់ឆ្កួតលីលីហើយ ពុំដឹងអី ។

ថនៈ តាវឿនហ្នឹង?

សៀនៈ បាទ! ប្រកាច់ម្ដងៗ ម៉ូតូអត់ហ៊ានជិះផង ។

ថនៈ បកទៅក្រោយវិញ និយាយថាអីរបស់ពូ ឈ្មោះជង់ហ្នឹង ពេលចាប់ហ្នឹងដូចពូដែររៀបរាប់មិញដែរ ជិះឡាន៣ហើយឲ្យទៅ?

សៀនៈ ទេ! គេចាប់គាត់ ខ្ញុំអត់ដឹង ខ្ញុំនៅអូរនេនាងនេះ ពេលគេទៅចាប់គាត់ ខ្ញុំអត់ដឹងទេ ទៅចាប់ឯភូមិខ្ញុំនោះណា ។ ស្ដាប់ គេថា គេហៅជួបពួកឡាយ ទៅដល់ឡាយហ្នឹងយំ ទៅដល់ឃើញអ៊ីខ្ញុំ ។ គាត់ក្លាចហើយរាគអាចម៍ពេញទាំងខោ ។ មានឈ្លប មាន៣នាក់ទៀត ៤នាក់ទាំងពួខ្ញុំនោះ ។ មួយនោះ មានឪធំ គ្រាន់តែឃើញពួកខ្ញុំទៅដល់ អ្នកដែលចាប់ហ្នឹងតែ៣ ឬ៤នាក់ ទេ គ្រាន់តែឃើញទៅដល់ទៅពីនេះ ពីរនាក់ ដល់អញ្ចឹង គេចាប់អានោះមក ទៅដល់អស់កម្លាំងរលីង ។ អាមួយនោះមាឪធំ ហក់ពីឡានដាច់ខ្សែបាត់ អាឆុនបាញ់អស់៣គ្រាប់ ងាប់នៅកន្លែងអាមួយមាឪធំ ។ ក្រៅពីហ្នឹង គេយកទៅមាត់ទន្លេទៅហើយ ពួខ្ញុំនោះគេដើរវាយក្បែរហ្នឹងឡានប្រហែលជា១០០ម៉ែត្រ ។

ថនៈ ថាឈ្មោះដួនហ្នឹងហេ៎?

សៀនៈ បាទ!

ថនៈ ហើយអ្នកវាយហ្នឹងឈ្មោះ អឿន?

សៀនៈ បាទ!

ថនៈ ចុះហើយដើរ ដូចថាអីរបស់ពូទៅជួបហ្នឹងទៅតាម?

សៀនៈ ទៅតា! ខ្ញុំទៅគ្នា៣នាក់ ទៅខ្ញុំម៉េចហ៊ានមាត់ និយាយផង គាត់ឲ្យខ្ញុំកាប់រណ្ដៅ កាប់មិនដឹងទាំងមុតដងក័យខែប្រាំង បើគាត់មានរណ្ដៅមានអីណា ។ កាលពីអត់មុតហ្នឹង ចាក់គាត់ហ្នឹងចំពុះទង់សុះអស់ហើយ ។

ថនៈ ឲ្យពួកកាប់រណ្ដៅ កាលនោះពូនៅអូរស្វាយ?

សៀនៈ នៅអូរនេនាង ។ នឹកឃើញខ្ញុំទៅស្រុកគេចេះតែសួរថា បងឯង ម៉ែខ្ញុំអី! ហើយប្រយ័ត្នមាត់កប្រយ័ត្នគេចោទកូនសម្លាប់ឯងសម្លាប់អីឯង? ហើយខ្ញុំថាអត់ទេ! ខ្ញុំថាក្លាចអីនឹងមាត់ បើប្រពន្ធគាត់នៅសព្វថ្ងៃ គាត់អត់យកប្ដីទេ ។

ថនៈ អូរនេនាងនៅឃុំអ៎?

សៀនៈ ពីមុនគេហៅឃុំអូរនេនាង ហើយឥលូវគេឈប់ហៅ ឃុំអូរនេនាងហើយ ឃុំសន្តិភាព ។

ថនៈ អឿនហ្នឹង គាត់អ្នកធ្វើផ្ទាល់ ឬក៏?

សៀនៈ បាទៗ!

ថនៈ ប៉ុន្តែគាត់ទៅ៣នាក់ ទៅជាមួយពូ?

សៀនៈ បាទ! ៣នាក់ ឈ្មោះ ពួកតាសយ ក្មេចឈ្មោះ អាហ្នឹងទាហានមជ្ឈិម តាក្មេចឈ្មោះតាមួយក្មេចឈ្មោះតែម្ដង ។

ថនៈ     តែមុនយកទៅថា តាវឿននោះសួរសចម្លើយ?

សៀនៈ អត់បានសួរចម្លើយ អត់សួរទេ ។ តាវឿន គាត់យកប៉ុន្មាននាក់ដែរទៅទន្លេបាត់ហើយ ខ្ញុំទៅជាមួយអឿន ជាមួយបងមួយនោះ៣នាក់ហ្នឹង នៅអូរនោងនៅមន្ទីរស្រុកគេហ្នឹង ។

ថនៈ     ខាងមន្ទីរស្រុកអីវិញហ្នឹងពូ?

សៀនៈ កាលនោះស្រុកសៀមប៉ាង នៅក្នុងអូរនោង គេហៅឃុំអូរនោង សព្វថ្ងៃគេហៅឃុំសន្តិភាព ។

ថនៈ     អញ្ចឹង គាត់នោះនៅមន្ទីរស្រុកតែម្តង?

សៀនៈ កាលហ្នឹង ខ្ញុំនៅមន្ទីរស្រុក ។

ថនៈ     និយាយថាជង់ហ្នឹង ចាប់មកមន្ទីរស្រុកតែម្តង?

សៀនៈ អត់ចូលមន្ទីរស្រុកទេ នៅចុងទំនប់ ។

ថនៈ     អញ្ចឹង មានទឹកន្លែងដូជជាវាល?

សៀនៈ វាលចុងទំនប់ វាលស្រែទំនប់អូរនោងហ្នឹង ។  ចាប់គាត់ពីភូមិ គត់ឡាំលិត គេចាប់គាត់ ។

ថនៈ     ចាប់ពីភូមិអី? ភូមិគត់ឡាំលិត?

សៀនៈ ភូមិគត់លំលិត!

ថនៈ     គត់ឡាំលិត ស្រុកសៀមប៉ាង?

សៀនៈ ហ្នឹងហើយ! កាលហ្នឹង គាត់នៅកាន់ គាត់នៅភូមិហ្នឹង ប៉ុនគាត់នៅកាន់ឃុំហ្នឹងមុន ។

ថនៈ     នៅកាន់ឃុំសន្តិភាពហ្នឹង?

សៀនៈ បាទ!

ថនៈ     អញ្ចឹង ភូមិហ្នឹង នៅក្នុងភូមិសន្តិភាពទេ?

សៀនៈ បាទ!

ថនៈ     អញ្ចឹងយកមក គាត់អត់និយាយអី ខាងនេះឆ្លងហ្នឹង គាត់អត់មានសួរអីដែរ?

សៀនៈ អត់ខាងឈ្លបហ្នឹង ដឹងតែគេចាប់គេទៅដល់ហ្នឹង បំបែកគ្នា គេបួននាក់ហ្នឹងអ៊ីគេបបួលគ្នា ៣នាក់ហ្នឹង គេដឹកយកទៅទន្លេ ។ តាវៀនហើយអ៊ីខ្ញុំ រំដោះចេញ មកឲ្យពួកខ្ញុំ៣នាក់ហ្នឹង យកទៅសួរចម្លើយទៅ ប៉ុន៣នាក់ហ្នឹងដែលគេយកទៅហ្នឹង មិនដឹងរស់មិនដឹងស្លាប់ទេ ព្រោះចាប់ដាប់វាយដល់ថ្នាក់ហ្នឹងហើយ មិនដែលរស់មកវិញទេ ។

ថនៈ     អ៊ីរបស់ពូហ្នឹង បានសួរចម្លើយបានដែរ?

សៀនៈ  សួរ!

ថនៈ     សួរអីខ្លះ?

សៀនៈ សួរថាខ្មែរឯងមានប៉ុន្មាននាក់? នរណាខ្លះហើយ បន្ទប់នៅឯណាខ្លះ? ថាគាត់អត់មាខ្មែរទេ គាត់ឆ្លើយថាអត់តែម្តង ។ អត់មានឆ្លើយថាមានខ្មែរបន្ទប់ មានក្បត់ មានអង្គការអី អត់មានទេ ។ សួរវាយ ចាក់ហ្នឹងចំពុះទង់ អីខ្ញុំចាក់សុះខ្លួន អត់ចង់ស្លាប់ទេណា ចាក់ហ្នឹងចំពុះទង់ ចាក់តាម ដែលអីខ្ញុំស្លាប់ចាក់សុះនៅហ្នឹងចំពុះទង់ វាយប៉ុន្មានចបហើយ បែកក្បាលហើយនៅតែអត់ស្លាប់ទេណា ។

ថនៈ អ្នកដែលសួរហ្នឹង អឿនហ្នឹង អ្នកសួរហេ៎?

សៀនៈ ឈ្មោះ អឿន ។

ថនៈ និយាយថាអ្នកធ្វើទារុណកម្មហ្នឹង ក៏អឿនដែរ?

សៀនៈ បងអឿន តែនបងអឿនម្នាក់ គានោះក៏អត់សួរដែរ គានោះក៏ខ្លាចដូចគ្នា ។

ថនៈ កាលនោះពូនៅក្បៀកជាមួយ?

សៀនៈ ខ្ញុំនៅជិតហ្នឹង! កាប់រណ្តៅ កាប់មិនមុតហ្នឹងភ័យ ។

ថនៈ ប៉ុន្តែភ័យហ្នឹងចង់មុខគាត់ ឬក៏អត់ទេ?

សៀនៈ បាទ! គាត់ឃើញ ។ គាត់ឃើញខ្ញុំ គាត់មានមាត់រកខ្ញុំ ខ្ញុំក៏មិនហានមាត់រកគាត់ ។ គាត់អត់មាននិយាយអីទាំងអស់ ។

ថនៈ ចុះគាត់អត់មានអ្នកផ្តែផ្តាំ អត់មានអីទេ?

សៀនៈ អត់ទេ! ស្ងាត់ជ្រាបអត់មាននិយាយអី១មាត់ គាត់និយាយច្រើនថាអត់មានក្បត់ពីអង្គការ គាត់ថាគាត់អត់ដែរមានខ្មែរដែរស្រឡាយអីបន្ទប់គិញសេ-អ៊ី-អា គាត់និយាយតែប៉ុណ្ណឹងឯងក៏គ្មានមាត់អីច្រើនទេ អត់មានស្រែកអត់មានអីទេ មានថ្ងូរអីទេ គិតទៅ ។

ថនៈ យូរហេ៎! រយៈពេលប៉ុន្មាន?

សៀនៈ ប្រហែលជា១ម៉ោងដែរ ម៉ោង៧ ទៅ៨យប់ ។

ថនៈ អញ្ចឹងយកទៅពេលយប់ទេ ពូណ៎ មានបិទភ្លើង បិទពន្លឺ?

សៀនៈ អត់ទេ! ពិលយើងហ្នឹង ។

ថនៈ ពូនៅពូថា! ចុះដូចថាប្រពន្ធកូនអីហ្នឹង អត់មានចាំបានទេ?

សៀនៈ អត់ចាំ! កាលនោះខ្ញុំឃើញ ឃើញចាប់តែប្តីទាំងអស់ អត់មានប្រពន្ធអីមកជាមួយទេ ។

ថនៈ ចុះក្រោយពីនិយាយថាចាប់អីរបស់ពូភ្ជង់ហ្នឹង ក្រោយមកពូមានទៅកន្លែងផ្សេងទៀត?

សៀនៈ អត់ដឹងទេ! យួនចូលស្រុកហើយ ។

ថនៈ កាលនោះឆ្នាំ ប៉ុន្មាន?

សៀន: ៧៨ហ្នឹង! នៅពាក់កណ្ដាល៧៨ហ្នឹង ជិតចុងហើយដែលខ្ញុំមកកូនក្មេងនៅសៀមប៉ាង១០០ នាក់ហ្នឹង ខ្ញុំ។

ថន: កាន់អីវិញពូ?

សៀន: កាន់ ទាហានចូលថ្មី ១០០នាក់។

ថន: អញ្ចឹងអ្នកចេញពីហ្នឹង មកភូមិមក?

សៀន: ចេញពីហ្នឹង តាវឿនគាត់ឲ្យខ្ញុំមកនៅស្រុកសៀមប៉ាងឲ្យកាន់ទាហាននៅហ្នឹង១០០។ ដល់មកនៅស្ទឹងត្រែង ខ្ញុំនៅកាន់ពួកក្មេងៗគេសម្រាប់បញ្ជូលទៅអង្គភាពណាស់ ឲ្យខ្ញុំហ្វឹកវីនក្មេងៗ ក្មេងៗអីខ្លះធំជាងខ្ញុំទៀត។

ថន: គេហៅអង្គភាពអីវិញពូ?

សៀន: អង្គភាពតំបន់ដែរ ប៉ុន្តែយកកូនក្មេងដូចថាជំទង់ៗសម្រាប់មកបង្ហាត់បង្រៀនដើម្បីនេះ ដូចថា អង្គភាពទាហានគេចង់បានបញ្ជូនទៅវាយនៅព្រំដែនអីចឹង ប៉ុនអត់បានទៅវាយណា បើយកទៅស្រុកទៅទាន់ រត់! រត់តាមផ្លូវហ្នឹង ខ្ញុំដឹកជញ្ជូន១យប់ហ្នឹង២ដើង។ ដឹកៗទៅឡានវាខូច ដាច់ក្រឡេនៅជិតម្ដុំក្រឡហ្នឹង ខ្ញុំថាមិនពិបាកទេ! មិនពិបាករត់ទេ បើស្រុកទៅអីទៅអីហ្នឹងវិញទៅ ឪពុកម្ដាយនៅឯណា ទៅហ្នឹងវិញទៅ ខ្ញុំមិនអាចយកទៅបានទេ។ មិនដឹងមេខ្ញុំនៅឯណាផង កាលនោះខ្ញុំបែកគ្នាពីមេខ្ញុំឈ្មោះ តា វឿន រត់ទៅខាងថ្ងានេះមក ខាងស្ទឹងត្រែងខ្ញុំនៅសៀមប៉ាង ខ្ញុំកាត់មកខាង ម្ដុំក្រឡអូរស្វាយ។ គាត់បកពីព្រៃហ៊ាងមកជួបខ្ញុំនៅនេះ នៅភូមិស្រឡៅ គាត់ដើររកពួកខ្ញុំ អាកូនក្មេង១០០នាក់ជាងហ្នឹង ខ្ញុំឲ្យទៅតាមស្រុកវិញអស់ទៅរត់ខ្ញុំថាមិនបាច់រត់ទេ។

ថន: កាលនោះចុងហើយ?

សៀន: បាទ! ចុងហើយ ៧៨ដែលយួនចូលហើយថ្មីៗនេះ។

ថន: វាយតាមព្រំដែន?

សៀន: បាទ! វាយចូលតាមព្រំដែន។

ថន: ក្មេងៗហ្នឹង ជ្រើសរើសមកពីណាវិញ?

សៀន: ជ្រើសរើសតាមភូមិមក ក្នុងស្រុកហ្នឹង ប៉ុនដល់កន្លែងហ្នឹងដីខ្ញុំកាន់កាប់ ខ្ញុំអ្នកទទួលខុសត្រូវណា ក្មេងទាំងអស់នោះ នៅមិនទាន់បានកន្លះខែផង នៃក៏រត់ណា រត់គិតទៅខ្ញុំដឹក ដឹកយកមកដាក់នៅអីនេះម្ដុំក្រឡនេះបាន១ដើងហើយ ដល់បកទៅវិញបានដឹកមកដល់ពាក់កណ្ដាលផ្លូវ វាដីខ្សាច់ខ្លាំងពេកដាច់ក្រឡេឡាន ឡានចិននោះ ដាច់ឡានចិនមិនដឹងទៅណាទៅណី តោះនាំគ្នាទៅ

ស្រុកទៅស្រែវិញតោះ ណាឪពុកម្ដាយទៅរកខ្ញុំទៅតែឯង ខ្ញុំក៏រត់មកគ្នា២នាក់ ៣នាក់ៗ អាប៉ុន្មាននាក់ អាខ្ញុំដឹងទៅដាក់នៅអូរ ស្វាយហ្នឹងណា ទៅតាមផ្ទះ តាមស្រុកនេះអស់ហើយ ។

ថនៈ ក្មេងៗហ្នឹង អ្នកជ្រើសរើសទាំងស្រី ទាំងប្រុសហ៎ពូ?

សៀនៈ ទេ! តែប្រុសទេ ។ ដូចថា ដូចសព្វថ្ងៃគេហៅថាសិស្សសាលា ប៉ុនកាលនោះមានណាបានរៀន បើខ្លះបានរៀន ខ្លះអត់ទៅជិនាន់ខ្មែរក្រហមនោះ ឬមួយជិទង់ៗយួនវាបុកតាមព្រំដែនខាងហ្នឹង គេឲ្យរើសមកដាក់កន្លែងមន្ទីរសិនៗ គេអង្គភាពនៅខ្លួនឯងត្រូវការអញ្ចឹង បញ្ចូលខ្លួនឯងទៅ កូនក្មេង ចុះគ្នាមិន ទាន់បានចូលណា ។

ថនៈ អាយុប៉ុន្មានច្រើនទេ?

សៀនៈ អាយុ១០ឆ្នាំ, ១២ឆ្នាំ, ៥ឆ្នាំ,១៥ឆ្នាំ, ខ្លះដល់២០ ធំជាងខ្ញុំទៅទៀត ។ ខ្ញុំតូចជាពួកវាផង ។

ថនៈ ចុះកាលហ្នឹង បែកគាវៀន បែក?

សៀនៈ បែក! ប៉ុនខ្ញុំនៅជាមួយគាត់នៅឡើយទេ ប៉ុនខ្ញុំអត់ឲ្យខ្ញុំគ្រប់គ្រង កូនក្មេងហ្នឹង ។ ខ្ញុំនៅឯស្រុក សៀមប៉ាងនេះ គាត់នៅឯស្ទឹងត្រែងនេះ ។ យូរៗ គាត់មកម្ដង ឲ្យគ្រប់គ្រងកូនក្មេង ឲ្យកាន់ កូនក្មេងនេះ ។ ដល់ទៅវាបែក ខ្ញុំឲ្យទៅតាមផ្ទះ ទៅតាមស្រុកវិញទៅ ។

ថនៈ ចេញពីនោះមកទៅណាទៀត?

សៀនៈ ខ្ញុំចេញពីនោះមក ខ្ញុំមកនេះរត់ឆ្លងមកខាងលិចទន្លេមេគង្គ មកនៅរត់កាលយើងអូរស្រឡៅ ។

ថនៈ ព្រះវិហារនេះ?

សៀនៈ បាទ!

ថនៈ កាលនោះ៧៩ទេពូ ឬក៏?

សៀនៈ ចុង៧៨ ។ ខ្ញុំរត់មកហ្នឹង មកនៅជិតគាវៀននៅកំពង់ស្រឡៅ ។

ថនៈ ហ៎ូ! គាត់រត់មកដែរ?

សៀនៈ បាទ! គាត់រត់ខាងនេះ រត់មកជួបខ្ញុំមកដឹកនាំកម្លាំងខាងនារីតំបន់៣០នាក់ជាង រហូតសព្វថ្ងៃ នោះវាខ្លះស្លាប់ ខ្លះបានប្ដី បានកូនីចៅអស់ហើយ ។

ថនៈ ហ្នឹងពូដឹកនាំមកតែម្ដង?

សៀនៈ បាទ! ខ្ញុំដឹកនាំរត់មក រហូតទៅដល់នោះ ទៅដល់ឯប៉ៃលិននោះ ។

ថនៈ កាលនោះរត់មកទេម្ដង ឬក៏អង្គភាពបញ្ជាឲ្យដកខាងតំបន់នោះ?

សៀនៈ ខាងតំបន់គេឲ្យដក ដកទៅក៏ជម្លៀសប្រជាជនដែរ ជម្លៀសវាអត់ទាន់ដែរ ។ កាលគេនោះថា ខ្ញុំយួនចូលស្រុកនោះ ធ្វើបាបប្រជាជន ជម្លៀសប្រជាជនបាន៣ ទៅ៤,១០កាណូតដែរ ប៉ុនយើងជម្លៀសអត់ទាន់ យួនក៏ព័ទ្ធ ព័ទ្ធយកទៅវិញអស់ទៅ ។ ប្រជាជនពួកខ្ញុំរត់តែពួកខ្ញុំទៅ ។

ថនៈ ជម្លៀសពីសៀមប៉ាងហ្នឹង?

សៀនៈ អត់រើសទេ! សៀមប៉ាងអីក៏ជម្លៀស គិតទៅនៅស្ទឹងត្រែងគឺជម្លៀសគ្រប់ ។

ថនៈ គ្រប់ស្រុកតែម្តង?

សៀនៈ ជម្លៀសចេញឲ្យផុត ។ ខ្លះក៏គាត់រត់បានពាក់កណ្តាលផ្លូវ ខ្លះឆ្លងមកដល់ព្រះវិហារនេះហើយ ប៉ុនដល់នេះយួនវាកាត់កៀរអស់ហើយ ។ ខ្ញុំក៏បែកពីប្អូនរបស់ខ្ញុំទាំងខ្ញុំបានទៅជួបបាន២ឆ្នាំ ។ នេះទើបតែ២ឆ្នាំ ឪពុកម្តាយខ្ញុំមិនដឹងថាខ្ញុំរស់នៅ ខ្ញុំរត់មកអន្លង់វែង រត់មកតាមនេះឯង ។ ឡានខ្ញុំចោលនៅទី១នេះ ១គ្រឿងក្នុងព្រៃ ទៅចោលនៅនេះមួយគ្រឿង ។ ឡើងទៅដល់អន្លង់វែងនោះ ផ្ទុះគ្រាប់បែកស្លាប់ម្នាក់ទៀត ។

ថនៈ នរណាគេអ្នកដាក់?

សៀនៈ តម្រង់ផ្លូវ! តម្រង់ផ្លូវព្រឹកឡើង ដល់គ្រាប់បែកក្រវ៉ាត់ចង្កេះ គ្រាប់បែកចិន វារបូតអាកន្លះ ផ្ទុះស្លាប់ម្នាក់ ។ ចេញពីហ្នឹងបានខ្ញុំទៅដល់វាយថ្មពួក វាយថ្មពួកយើងបន្ទាយមានជ័យ បន្ទាយឆ្មារ ខ្ញុំនៅបន្ទាយឆ្មារប្រហែលជា១ខែជាង វាយនៅហ្នឹង វាយឆេះរថក្រោះ ឆេះអីរំដោះដើរប្រមូលប្រជាជនឲ្យគាត់មកផ្ទះវិញ ១ផ្លូវបន្ទាយឆ្មារ ។

ថនៈ វាយជាមួយនរណាខាងរដ្ឋាភិបាលហ្នឹង?

សៀនៈ ជាមួយរដ្ឋាភិបាល! មិនមែនជាមួយរដ្ឋាទេ គឺជាមួយយួន ។

ថនៈ កាលនោះដូចជាមានហ៊ុន សុិនប៉ិចអីដូចជាឈរជើងនៅទីនោះដែរ?

សៀនៈ កាលនោះមិន ហ៊ុន សុិនប៉ិច មិនទាន់បានវាយនៅឡើយទេ ព្រោះហ៊ុន សុិនប៉ិចនៅជុំនៅឡើយទេ ។ តែខ្មែរក្រហមសុទ្ធទេកាលហ្នឹង ពួកខ្ញុំវាយនៅ ខ្ញុំឈរជើងនៅបន្ទាយឆ្មារ វាយស្រុកថ្មពួក ហើយខ្មែរក្រហមៗ អត់ត្រូវគ្នាទេកាលនេះ ក៏ឧត្តរមានជយ័នេះ ខាងពួកខ្ញុំមកពីក្រចេះ មកពីស្ទឹងត្រែងនោះអត់ត្រូវគ្នា វាយគ្នាទៀត ។

ថនៈ អត់ត្រូវ អត់ត្រូវម៉េចដែរ?

សៀនៈ អត់ត្រូវខាងគេនោះ ហើយចោទពីពួកខ្ញុំមកពីនោះថាយួនមក គេហៅថាពួក៥០០០ពួកខ្ញុំ ។ មកពីនោះ៥០០០នាក់នោះពីក្រចេះ ពីស្ទឹងត្រែង ។ អញ្ចឹងពួកខាងកងទ័ព ពួកខាងឧត្តរមានជ័យនេះ ខាងតាគេម ខាងតាអយ ខាងតាស្រស់នេះគឺថា ពួកមកពីឡសាននោះ ពួកក្រចេះ

ស៊ឹងត្រែងនោះ ពួកខ្ញុំនោះនាំយួនមក ប៉ុនពួកខ្ញុំគេចពីយួន! វាយគ្នានៅគូ ភូមិគូយើងអំពិល នេះ វាយសាប់គ្នាឯង ។

ថនៈ វាយខ្លាំងដែលពូហេ៎?

សៀនៈ បាទ! វាយខ្លាំងដុតឡាន ដុតអី តាសឿនមេភូមិភាគឧត្តរ ពួកគេអ្នកវាយ ។ វាយគ្នា បានដុតពីហ្នឹងពួកខ្ញុំទៅនៅបន្ទាយឆ្មា អាហ្នឹងបានវាយគ្នា បើកផ្លូវឈានរហូត ជាមួយយួនវាកាត់ទៅ ដល់ថ្មពួក វាយថ្មពួក ប្រមូលស្រូវចែកប្រជាជន ដល់ប្រមូលប្រជាជននៅតាមព្រៃគាត់ឃើញ យើងខ្លាច ប្រមូលគាត់ឲ្យមកនៅតាមផ្ទះវិញ ។ ដល់ទាហានវាបុកមកពួកខ្ញុំរត់មក ទៅព្រិច រួចគោករមៀត ចេញពីហ្នឹងធ្លាក់បានឆ្លងទៅថៃចូលព្រៃមាន់ ចេញពីព្រៃមាន់ បានកម្លាំងទ័ពធំដើរថ្មើរជើងតាមក្បួនដីធ្លាក់ទៅអូរជ្រៅ យួនវាយសាប់នៅហ្នឹងច្រើន ។ បានពួកខ្ញុំធ្លាក់ទៅបារាំង ធ្លាក់ទៅអូរអន្ទក់ តាមជម្រាល ទៅនៅហ្នឹង វាយនៅហ្នឹង ពួកខ្ញុំវាយនៅជួរកំពង់ឡេង បរិលពពិល៥ ដើមមក ។

ថនៈ ពូកាលរត់ពីស៊ឹងត្រែងមក ព្រះអង្គលអីមកច្រើនទេគ្នាទេពូ?

សៀនៈច្រើន! បាទ គិតទៅទាំងប្រជាជន ទាំង! គិតទៅប្រជាជនច្រើន ប្រជាជនរាប់ម៉ឺន ប៉ុន្តែដល់នេះគាត់បកទៅវិញ យួនកាត់ផ្លូវ យួនកៀងទៅវិញ ។ អាពួកមន្ទីរកន្លែងខ្ញុំ ក៏ទៅវិញអស់ខ្លះ យួនកាត់យកទៅវិញអស់ខ្លះ ។

ថនៈ គាត់ទន្លេតែម្តង?

សៀនៈ អត់ទេ! វាឆ្លងទន្លេ យួនវាកាត់កៀង ។

ថនៈ អត់ទេពូ! និយាយពូមកព្រះវិហារ យើងមិនឆ្លងទន្លេពីរ ។

សៀនៈ បើខ្ញុំឆ្លងអូរស្វាយ ឆ្លងទន្លេតែមួយទេ ទន្លេមេគង្គបានមកធ្លាក់ព្រះអង្គល់ ឆ្លងទូក! យើងដែលជម្លៀសអត់ទាន់ដោយសារវាតូច បានមកនាព្រះអង្គល់ប្រហែលបាន១អាទិត្យ បានខ្ញុំមកនៅមកអូរស្រឡៅ ព្រំប្រទល់លាវ ។ ខ្ញុំបានជួបម្តាយខ្ញុំនៅព្រះអង្គល់ ជាមួយបងខ្ញុំ បែកៗ គេកៀងទៅលាវម្តាយខ្ញុំ ។ អ្នកស្រុកខ្ញុំអត់បាននៅស្រុកដែលហ្នឹង ដល់ពួកខ្ញុំផ្តាច់ខ្លួន ពួកខ្ញុំមកពីលាវ ខ្ញុំទៅស្រុក!

ថនៈ គាត់ទៅនៅលាវតាំងពី?

សៀនៈ តាំងពី៧៨ គាត់រត់គេចពីយួនហ្នឹង គាត់មានបកមកស្រុកវិញ រត់ឆ្ងាយទៅលាវ ។ បែកបាក់គ្នាទៀត បងប្អូនខ្ញុំនោះ ខ្លះនៅខ្មែរ ខ្លះនៅលាវ ទេកាលនោះបានមកជុំគ្នាវិញ ។ ហើយខ្ញុំទើបទៅជុំក្រោយគេទៅជួបក្រោយគេ ទើបឆ្នាំទៅមួយ ខ្ញុំទម្រាំតែរកឃើញភូមិស្រុកឃើញ

ទៅដេកនៅស៊ីងត្រែងមួយអាទិត្យ ឥលូវគាត់ឈប់នៅស៊ីងត្រែងហើយ គាត់នៅនោះ។ ដីនៅស៊ីងត្រែងនោះ គេយកអស់រលីង អ្នកភូមិចាមគេនៅអស់ ។

ថន: នៅទីរួមខេត្តតែម្តង?

សៀន: បាទ! នៅជិតគ្នាតែម្តង ទៅដល់ដើរទៅរកសួរគេអស់ហើយអ្នកស្រុកហ្នឹង ខ្ញុំទៅសួរគេទៅដេកនៅកន្លែងភូមិភាគ គេចេះតែឆ្ងល់ ចុមគាត់មកនៅអន្តុយនៅកំពង់ដែរវាល់ថ្ងៃ សួរៗ មានស្គាល់ឈ្មោះចេះៗ អត់មាននរណាស្គាល់! អ្នកភូមិទៅលាវអស់ហើយ ១អាទិត្យ! ១អាទិត្យហ្នឹងស្គាល់តាមអ្នកសៀមប៉ុងហើយ ឪពុកម្តាយបងប្អូនខ្ញុំឈ្មោះចេះៗ ខ្ញុំក៏ទៅតាមគេ ឃើញអាប្រេងសម្រាប់ចាក់ការណូតគេ ទៅដល់ ជួលគេហើយចាក់ប្រេង ហើយទុកចោល គេហៅភូមិកោះចាស់ ។ ទៅដល់ភូមិកោះចាស់ហ្នឹង សួរគេ គេអត់ស្គាល់ម្តាយខ្ញុំសោះ ។ ជិតមកនេះវិញ! ទម្រាំបានជួបហ្នឹងក្មួយខ្ញុំហើយទៅលេង សួររកហើយថា ម្តាយខ្ញុំហ្នឹងយាយវា ។ ខ្ញុំថាប្អូនឯងកូននរណាហ្នឹង? កូនបងខ្ញុំ កាលខ្ញុំនៅស្រុកមិនទាន់មាន កូនតូចៗ! កូនបងខ្ញុំ ។ ដល់ខ្ញុំទៅដល់ថា យាយខ្ញុំ ឈ្មោះគាយ! ម៉ែខ្ញុំ បានដឹងបានជួប ។

ថន: ឆ្នាំ ប៉ុន្មានពូ?

សៀន: បាទ?

ថន: និយាយថាឆ្នាំប៉ុន្មានពូ?

សៀន: ឆ្នាំ២០១២ ។

ថន: ទើបតែឆ្នាំមុនហ្នឹង?

សៀន: បាទ!

ថន: តាំងពីពូចេញពីភូមិមក?

សៀន: បាទ! ៧៨ហ្នឹង ខ្ញុំជួបម្តាយខ្ញុំបាន២ដង ។ ៧៧ ខ្ញុំជួបម្តងដែលខ្ញុំឈឺ ខ្ញុំមកពីព្រំដែន ខ្ញុំឈឺ ខ្ញុំមក ដេកពេទ្យស្រុក ។ ដល់ពេលមកដេកពេទ្យស្រុក ម្តាយខ្ញុំដឹង គាត់សុំអង្គភាពខ្ញុំយកទៅព្យាបាលនៅឯផ្ទះ ដល់ខ្ញុំជា ខ្ញុំមកអង្គភាពខ្ញុំវិញ ។ ដល់៧៨ដែលរត់ រត់យួននេះ ខ្ញុំជួបគាត់បាន២ថ្ងៃ នៅ ផ្ទះគាត់! ដែលខ្ញុំថាជួបគ្នាពីនាក់បងនោះ អត់បានជួបម៉ែទៀត ។ ចុះយើងខ្លាចមេយើង នោះ ជួបម្តាយហើយអត់ហ៊ាន ។ អត់មានបានបេះដូងឲ្យគាត់ អ្នកផ្ទះគាត់លក់ហើយនៅតែផ្ទះដើមដូង ហើយដើមស្វាយ ។ ពួកខ្ញុំទៅដល់ហ្នឹងខុះអីដើមដូង! បានចេះតែរត់មករហូត សព្វថ្ងៃ ។

ថន: ហើយពូទើបតែជួបនៅថ្មីៗនេះទេ?

សៀនៈ ខែ៨នេះ ទៅទៀតហើយ ទៅការក្មួយ ។

ថនៈ ខែ៨ឆ្នាំក្រោយនេះ! ចុះពូចង់សួរ ដល់ពេលពូទៅដល់អើកំពង់ស្រឡៅព្រំដែនលាវ កំពង់ស្រឡៅ នៅស្រុករវៀង?

សៀនៈ ស្រុកឆែប!

ថនៈ ខេត្តព្រះវិហារ!

សៀនៈ ខេត្តព្រះវិហារ ។

ថនៈ ទៅហ្នឹង! ពូត្រលប់ទៅខេត្តស្ទឹងត្រែងវិញ?

សៀនៈ អត់ទេ! មកចេញពីកំពង់ស្រឡៅហ្នឹង ខ្ញុំមកស្អាងនេះ ។ ស្អាងយើង ស្រុកឆែបដែរ ប៉ុនមកនេះជិតជ័យសែនដែល ជ័យសែនព្រះវិហារ មកនៅនេះ ដល់រកគាវៀនឃើញហើយ ឲ្យគេជូនមកនេះមកនៅយើងនែ៎ក បាក់អន្ទង់ត្រពាំងប្រាសាទ វាយកន្ទុត ចា៎! រាល់ថ្ងៃនេះវាយហ្នឹង ។ អស់ផ្លូវអស់អី ទៅលែងរូចចុះឡាន ចុះអីទៅតាមគេ ថ្មើរជើងរហូតតាមព្រំដែនទៅដល់ពាយព្យ ។

ថនៈ គេរៀបម៉េចដែរពូ ដល់ពេលមកដល់ព្រំដែនលាវ អង្គភាពយើងនៅដដែល ឬក៏បញ្ចូល?

សៀនៈ កាលហ្នឹងមិនទាន់មានអង្គភាពទេ មិនទាន់បានជួបអង្គភាពទេកាលហ្នឹង កំពុងដើររកមេ រកគាវៀន ។ កាលបែកគ្នា គាត់នៅស្ទឹងត្រែង ខ្ញុំនៅសៀមប៉ាង កាលហ្នឹងខ្ញុំកាន់កូនក្មេង ដល់ពេលយួនចូលស្រុកមក គាត់នៅខាងយើង ខាងព្រះវិហារ ខាងគេហៅឫស្សី ខាងស្រុកថ្លា ខ្ញុំរត់ចេញពីសៀមប៉ាងឆ្លងមុខអូរស្វាយហ្នឹង ឆ្លងមកព្រះគ្គល់ ។ ចេញពីព្រះអង្គល់បានមកកំពង់ស្រឡៅ ចេញពីហ្នឹង បានខ្ញុំជួបមេហើយ បានខ្ញុំមកយើងស្អាងនេះ យើងមកស្រុកនែ៎ក ជ័យសែន ។ ខ្ញុំនៅជ័យសែន ប្រហែលជាបាន១អាទិត្យ ខ្ញុំបកមកជាំក្សាន្តនេះ មកជួបពួកម៉ាកខ្ញុំអារុន១ គេកាប់ដាច់កំប៉េះគូទ ប៉ុនស្លាប់បាត់ហើយអានោះ ។

ថនៈ នរណាគេកាប់ពូ?

សៀនៈ ប្រជាជនកាប់! ទៅជម្លៀស ទៅជម្លៀសប្រជាជនហ្នឹង បាន១ទូក ២ទូកហើយ ស្រាប់តែទៅ១ទូកសារក្រោយហើយ ប្រជាជនដេញកាប់ធ្លាក់ទឹកទន្លេ កុំតែបានទឹកហ្នឹង ងាប់បាត់ កាប់ប្រវែង១នេះ ។ ខ្ញុំជួបវាញហ្នឹង មកជួបនៅជាំក្សាន ។ នៅជាំក្សានហ្នឹង វានៅខាងនេះ វាជិះឡានមក វារត់មក វាដើរអត់រូច ជួបវាថាផ្ញើរវានៅស្រុកជាំក្សាន្តនេះ ។ កាលហ្នឹងខ្ញុំនៅ អង្គរក្សគាវៀនដែរ ។ អាហ្នឹងវាជិនាងគាឡាយដែរ ដៃដល់ ។ ទុកវានៅហ្នឹង មិនដឹងជាយ៉ាងទៅជាហើយវាជួបគ្នា នៅឯនោះ ហួសអន្ទង់វែងទៅជួបវា ។ វាជាវាសះហើយទៅជួប រត់មកតាម

អគ្គភាពនោះ ទៅជួបពួកខ្ញុំបានទៅនៅជាមួយគ្នាវិញ ។ ឥលូវវាស្លាប់ទាល់តែបាន ស្លាប់ពីរឆ្នាំហើយ ។

ថនៈ អញ្ចឹងពេលពូនៅ មកជួបនៅព្រំដែនលាវនោះ អត់ទាន់មានរៀបចំជាអគ្គភាពទេ?

សៀនៈ ចាំមើលខ្ញុំនិយាយណា៎! ខ្ញុំរត់! ពេលនោះអគ្គភាពយើងទាំងអស់គ្នា ទាំងអគ្គភាពដែលមកពីភូមិភាគនោះគឺ រត់ៗសំដៅទៅអគ្គការប៉ុល ពត ថ្នាក់ដឹកនាំធំ ។ កាលហ្នឹងពួកខ្ញុំរត់ដែលយួនចូលស្រុកនេះរត់រកអ្នកដឹកនាំ ដូចថាតាប៉ុល ពតអញ្ចឹងអ្នកដឹកនាំ រត់សំដៅគាត់ហ្នឹងហើយ ។ បេះរត់ៗ ទៅមួយសារហ្នឹង កុំតែយួនចូលពេញអាចរត់ទៅដល់កោះកុង ខ្ញុំណា៎ គ្រាន់តែទៅដល់ពួកខ្ញុំមកជួបជុំគ្នានេះ មកជួបជុំគ្នាត្រឹមអន្លង់វែងនេះ ជួបជុំអគ្គភាព ។ ជួបជុំនៅអគ្គភាពនៅអន្លង់វែងបានបេះតែរត់ អាននេះកើតជាអគ្គភាពហើយណា ។ រៀបចំជាវរៈ ជាអនុសេនាធំ ជាអីតាមកងៗ គេរៀបចំធ្វើដំណើរមានតែកងការពារ កងពិសេស កងថ្មើរជើងសម្រាប់ការ ពារប្រជាជន គ្រួសារទាហានអី ទាហនអីវាយកាត់ក្រោយនេះ រកវាយគ្នារហូតតាមផ្លូវ ។ អាហ្នឹងរៀបចំកងៗបានទៅដល់ បន្ទាយឆ្មារពួកត្រឹមហ្នឹង បានប្រហែលជ៦១ ខែជាង បានវាវាយរំដោះយកស្រូវ យកអង្ករអី ប្រមូលប្រជាពលរដ្ឋមកជញ្ជូនចែជន្យ អីទាហានវាបុកទៀត អត់ចេញពីហ្នឹងទៀត ទៅនៅឯគោកមាស គោកពេជ្រ ។ បានទាហានបុកនៅគោកមាស គោក ពេជ្រហ្នឹង ទៅនៅព្រៃមាន់ បានចូលភូមិថៃ បានកម្លាំងធំថ្មើរជើងមកតាមអូរជ្រៅ វាយស្លាប់នៅអូរជ្រៅច្រើនណាស់ ។

ថនៈ កាលនោះរយៈពេលប៉ុន្មានពីនេះទៅ យើងធ្វើដំណើរ?

សៀនៈ អូរច្រើនខែណាស់លោកគ្រូអើយ! ប្រហែលជា២ ខែ៣នោះ ។

ថនៈ អញ្ចឹងនៅក្នុងឆ្នាំ១៩០០?

សៀនៈ ៧៨!

ថនៈ ៧៨?

សៀនៈ ៧៨ រត់! ពួកខ្ញុំរត់៧៨ហ្នឹង ។

ថនៈ អញ្ចឹងអត់មានបានឡើងទៅដល់១០០១អីទេ?

សៀនៈ ដល់! ចាំមើលខ្ញុំនិយាយ ។ ខ្ញុំចេញពីហ្នឹង ព្រៃមាន់កម្លាំងធំគេបុកមកអូរជ្រៅប៉ោយប៉ែតនេះ ។ ៨១៧ គេឲ្យបុកមក ឲ្យចូលប៉ោយប៉ែត! យួនបាញ់ទម្លាក់ទឹក ទាំងស្រីទាំងប្រុសស្លាប់រាប់រយនាក់នៅហ្នឹង ។ ខ្លួនខ្ញុំចូលព្រៃមាន់ បានថៃដឹកទៅអូរក្រូងក់ ភ្នំក្រូងក់យើងនៅអូរល្ហុងនេះណា៎ នៅម៉ាឡៃ ។ នៅហ្នឹង បានរៀបចំជាអគ្គភាពទុកកម្លាំងដឹកនាំប្រជាជនខាង

តាមុន តាឃឹមហ្នឹង គ្រប់គ្រងប្រជាជន កាលហ្នឹងនៅ៨០១ យកកងពល៨០១ណា៎ៗ តាមុន គាត់កាន់ខាងទ័ព វាយនៅត្រាវ នៅកម្រៀងនេះ អូរដាវ មួយជួរ វត្តកោស៊ូ វាយភ្នំកុយ, ខ្មោ, អូរចំបក់, អូរចម្លងៗ

ជនៈ តាវឿន គាត់នៅ៨០១?

សៀនៈ បាទ! កាលហ្នឹងទៅពីនេះ គេប្រជុំជាមួយ៨០១ៗ កាលហ្នឹង គាត់នៅ៨០១ ដែលដាច់ពីភាគឦសាន គាត់កាន់ទាំងអស់ដែលរត់ទៅខាងនេះៗ បើខាងនោះ ៨០១ អង្គភាពតា០៥ តា០៥ខាងនោះៗ ដល់ពេលតាវឿន គាត់មកនេះ ពីមុនគាត់គណៈតំបន់ ដល់ពេលគាត់រត់មកបេះ ៨០១ដែលដាច់មកនេះគគឺតាវឿនអ្នកកាន់ ដឹកនាំជាអង្គភាព៨០១ៗ ប៉ុន្តែទៅដល់យើង ត្រាវ កម្រៀងនោះ ជួបជាមួយតាចៀម ស្គាល់តាចៀមទេ?

ជនៈ តាចៀម គាត់នៅហ្នឹងដែរ?

សៀនៈ នៅមន្ទីរ តាប៉ុល ពតៗ តាចៀម, តាចែៗ

ជនៈ តាចៀមមួយជាជនជាតិហ្នឹងហែ៎?

សៀនៈ ហ្នឹងហើយៗ ទៅដល់ តាចៀម គាត់រៀបចំឲ្យពួកអង្គភាពពួកខ្ញុំហ្នឹង៨០១ហ្នឹង រៀបចំ១វរសេនាធំ និងប្រមូលកម្លាំងឲ្យដាច់ៗ ដល់រត់ពីភ្នំពេញ ពីអឹមក ពីសហជីប ពីអង្គភាពដូចថាព្រោះខ្ញុំវាយនៅឯបឹងស្នឹង កម្រៀងហ្នឹងហើយ កំពង់ឡេង មួយជួរហ្នឹងហើយៗ មើលធ្លាក់របស់គេនៅទន្លេនែ៎ក រៀបចំពី៩៤៨, ៤៦០ ពួកកងកំពង់សោមដែលដាច់អង្គភាពប្រមូលទាំងអស់គ្រប់អង្គភាព គឺចូលៗ ប្រមូលអង្គភាពដែល វង្វេងដែលបែកបាកគ្នាទៅ ប្រមូលយកមកដាក់អង្គភាពខ្ញុំៗ ប្រមូលដាក់អង្គភាពខ្ញុំបាន ចូលក្នុងអង្គភាពខ្ញុំហើយ អង្គភាពណាហើយដាច់ឃើញ ជួបតាមព្រៃ តាមផ្លែវយកដាក់ៗៗ បានខ្ញុំនៅហ្នឹង ដល់ឆ្នាំ៨១ អញ្ចឹងគេដកអង្គភាពពួកខ្ញុំហ្នឹងឲ្យបើកព្រំដែនតាមព្រំដែន ឆ្នាំ៨១ហ្នឹងណាៗ ដកពីអង្គភាពហ្នឹង បើកផ្លូវតាម គេដកពួកខ្ញុំមក៨០៨តាមជួរភ្នំហ្នឹង ទាក់ទងថៃក្រហមៗ ថៃក្រហមវានៅហ្នឹង ទាក់ទងប្រកៗហ្នឹង ខ្ញុំហ្នឹង ប្រមូលគ្នា ដូចថាដាច់ខ្សែរយៈ តាមអង្គភាពខេត្តកណ្តាល, កំពង់ធំមក, ចុះទៅយកអឹខៀវៗ ខ្ញុំហ្នឹងទៅយក ចុះស្តាយអង្គរ,សារុង,ក្រណាត់, ហៅនៅតាមព្រៃតាមអឹមកជួបនោះអ្នក ដែលខ្សែរយៈ ឲ្យហៅរកអ្នកដាច់ និងវង្វេងព្រៃ វង្វេងអីណា៎ ដូចថាដាច់បាយដាច់ទឹកតាមព្រៃ ប្រមូលយកមកនៅលើភ្នំៗ ពួកខ្ញុំហ្នឹងដើរទាក់ទងពួកនេះ គេហៅពួកប៉ារ៉ាហ្នឹង ខាងសម្តេចសឺន សាន សម្តេចសីហនុ គេមិនទៅជាមួយថៃៗ ទាក់ទងទម្រាំដឹងថាដានគេ ទៅសរសេរដាក់ហ្នឹងថ្ម ថាខ្មែរហ្នឹងគ្នា អត់វាយគ្នា រួបរួមគ្នាវាយយួនបេះហែ៎ អត់

ឃើញជួបត្រៀម អ្នកស្រុកគេមក តាមអូរហ្នឹងព័ទ្ធ ព័ទ្ធក៏ជួបគ្នា ទាក់ទងផ្លូវគ្នា ប្តូកខ្ញុំកាលហ្នឹង ដល់ថៃក្រហម ក៏វាដកចេញទៅ ជូនអគ្គរជូនអីវ៉ាទៅ ចេញពីនោះពួកខ្ញុំបានបើកផ្លូវ ឲ្យថៃដឹក មក ហើយចុះទៅយកកម្លាំងដោយ ប្រមូលអគ្គភាព អគ្គភាពណាក៏ដោយ ឲ្យតែដាច់បាយ ដាច់ទឹកយកខោអាវទៅចែកឲ្យនាំមកលើភ្នំ។ រហូត១០០២ ហើយឲ្យដាន យើងដានអាន សេស។

ថនៈ ១០០២ ពីណាទៅដល់ណាពូ?

សៀនៈ ១០០២ ហួស! អានេះ១០០៣នេះ។ ១០០៣ហ្នឹង គេហៅអូរក្រញូងហើយ១០០៣ ហ្នឹង។

ថនៈ ១០០២ គេហៅអីវិញ?

សៀនៈ ១០០២ គេហៅអានសេស។

ថនៈ អាហ្នឹងនៅមួយជួរព្រះវិហារដែរ?

សៀនៈ នៅព្រះវិហារដែរ មួយជួរប្រាសាទអ្នកបួស មួយជួរអំពិលព្រិច។

ថនៈ អូរក្រញូង! អញ្ចឹង ពូនៅមួយជួរនេះដែរ មួយជួរអានសេសសែរដែរ?

សៀនៈ បាទ! អានសេសក៏នៅ និយាយរួមមួយជួរនេះខ្ញុំនៅទាំងអស់។ អានសេស,១០០៣, អូរ ក្រញូ, អូរ៥០នេះ ខ្ញុំនៅទាំងអស់។

ថនៈ ៤១៧ យើងឈរជើងនៅបន្ទាយឆ្មារ ឬមួយក៏?

សៀនៈ ៤១៧ នៅបន្ទាយឆ្មារ! ដល់ក្រោយមក ទៅនៅជុំ ទៅវាយនៅកម្រៀង,ត្រាង នៅបឹងឆ្នាំង នៅបៃលិន។ តា ស៊ូ កាន់កន្លែងហ្នឹង! តាស៊ូអី តាឈៀង, តាអ៊ី ឈាន។ អ៊ី ឈានពីមុន គាត់នៅមន្ទីរតាប៉ុល ពត។ ប៉ុនអគ្គភាពហ្នឹង អគ្គភាព៤១៧ អ្នករត់ទៅពីនេះ។ ដល់ពួក ៤១៧គេនៅហ្នឹងទៅ អ៊ី ឈាន គាត់កាន់កាប់ ហើយពួកខ្ញុំបកមកនេះវិញ ខាង៨០១ណាំ បក មកតាមព្រំដែន មកបើកច្រកនេះរហូតដល់១០០១។ ១០០១ នេះបើច្រកក្រោយគេ ខ្ញុំ ហើយទៅបើកផ្ទាល់។

ថនៈ ហើយមួយណាកើតមុនគេ?

សៀនៈ កើតមុនគេ ៨០៨។

ថនៈ ៨០៨?

សៀនៈ បាទ!

ថនៈ អាហ្នឹងគេហៅអីវិញ?

សៀនៈ គេហៅប-១ ។ ប្រាច់ ប-១ ដាប់ភូមិប្រាច់!

ថនៈ អាហ្នឹងកើតីមុនគេតូ?

សៀនៈ មុនគេអាហ្នឹង! អានេះត្រឹមខាងលិច បើកើតមុនមានតែនេះត្រាងកម្រៀង ហើយនៅបឹងបេង ។

ថនៈ ម៉ាខ្សែ?

សៀនៈ បាទ! បន្ទាប់មកនេះប-១ ហៅ៨០៨ ។

ថនៈ មួយទៀតត្រាងណាំពូណាំ?

សៀនៈ បាទ!

ថនៈ បន្ទាប់មកបឹងបេង បន្ទាប់មក៨០៨ប-១ ហើយចុះ១០០១,១០០២,១០០៣?

សៀនៈ ១០០២ បន្ទាប់ពី ៨០៨ហ្នឹង ។ បន្ទាប់ពី១០០២ ទៅក្រោយគេ១០០១ ។

ថនៈ ចុះ១០០៣?

សៀនៈ ១០០៣នេះឯង បន្ទាប់! ១០០៣ កើតក្រោយ១០០២ ។

ថនៈ ១០០២ ហើយបាន១០០៣ ហើយបាន១០០១ ឬក៏យ៉ាងម៉េច?

សៀនៈ ចាំមើលណាំ! ៨០៨ ហើយបាន១០០២, ១០០២ ហើយបាន១០០៣,១០០៣ ហើយបាន១០០១ក្រោយគេ ។ ហើយអ្នកអត់ដឹងនោះ កុហកចាញ់ខ្ញុំហើយ ព្រោះខ្ញុំអ្នកដើរបើកប្រកតាមហ្នឹង ។

ថនៈ បាទ! ចឹងមួយត្រាង ហើយបានបឹងបេង!

សៀនៈ ហៅបារាំងធ្លាក់ហ្នឹងណា ។

ថនៈ ហៅបារាំងធ្លាក់ ។

សៀនៈ នៅមួយជួរអូរល្ហុងហ្នឹង ចេញពីហ្នឹងបាន៨០៨ ។ ៨០៨ គេហៅប-១ ។

ថនៈ ៨០៨ ប-១ អាហ្នឹង នៅម្ដុំ?

សៀនៈ ជាមួយគ្នាហ្នឹង ប៉ុនគេហៅ ។

ថនៈ អាហ្នឹងនៅមួយជួរណាវិញទៅ៨០៨?

សៀនៈ មួយជួរប្រាច់យើងនេះ ប្រាច់បុទម ប្រាច់នៅភូមិថៃ ។

ថនៈ បុទមហ្នឹងនៅឯថៃដែរ?

សៀនៈ បុទមនៅថៃដែរ ។ អាហ្នឹងតំបន់ខ្មែរក្រហមណាំ មិនមែនតំបន់ប៉ាវ៉ាទេណា ។ បន្ទាប់មកនៅ១០០៣ បន្ទាប់ពី៨០៨មក បាទ! ១០០២ បាន១០០៣ ។

ជនៈ ពីណាដល់ណា ១០០២?

សៀនៈ ចាប់ពី១០០៣ ទៅអានសេស អាហ្នឹង ១០០២ហើយហ្នឹងៗ ចាប់ពី ១០០២មកលើ ទៅព្រលានតាសេក ។

ជនៈ ១០០២ ហើយ១០០៣ហេ៎?

សៀនៈ អាហ្នឹងហើយ១០០៣! អាហ្នឹងបញ្រ្ចាស់មកវិញទេណ៎ា ។ ១០០២វានៅខាងនោះ ១០០៣ ប៉ុនអា១០០៣នេះវាកើតនៅក្រោយ១០០២ទេ ប៉ុន១០០៣នៅនេះទេ ។ ប៉ុន១០០២ នៅឯកើតនោះ ។

ជនៈ បាទ! ខ្ញុំគ្រាន់តែចង់ដឹងថា១០០២ ហើយដល់ ១០០៣ ហើយ ១០០១ចុងក្រោយហេ៎?

សៀនៈ បាទ! ចុងក្រោយ ។

ជនៈ គ្រាន់តែចង់ដឹងព្រំប្រទល់ ១០០៣ ពីណាដល់ណា?

សៀនៈ ២០០២ ឬក៏២០០៣?

ជនៈ ១០០៣!

សៀនៈ ១០០៣ ក្រោយគេអានេះ យើងវាភ្លោះ យល់ខ្ញុំនិយាយទេ ។ ពី៨០៨មក មិនទាន់៨០៨ ទេ វាមាន១០០២ មុន ប៉ុន១០០៣នៅនេះ វានៅកណ្តាលនេះ ។

ជនៈ ប៉ុន្តែ ខ្ញុំចង់ថាមួយណាវាកើតមុនណា? ១០០២ កើតមុនហើយមែនទេ?

សៀនៈ នែ៎ក! កើតមុន ១០០៣ ។

ជនៈ អញ្ចឹង១០០២ ហើយ១០០៣?

សៀនៈ បាទ!

ជនៈ ប៉ុន្តែ ខ្ញុំគ្រាន់តែចង់ដឹងព្រំប្រទល់នៅម្តុំហ្នឹងតែម្តង ឬ?

សៀនៈ បាទ! ១០០៣នៅនេះ នេះ១០០៣ ។

ជនៈ ១០០៣ ព្រះប្រឡាយ?

សៀនៈ បាទ! ឈូករុន ។ អូរក្រញ៉ូង ព្រះប្រឡាយ ។

ជនៈ ឈូករុន, អូរក្រញ៉ូង, ព្រះប្រឡាយ ។ ហើយចុងក្រោយគេ ១០០១?

សៀនៈ អាហ្នឹងករណីចុងក្រោយគេ ។

ជនៈ ខាងតា សុន សេន?

សៀនៈ បាទ! ខាង តាសុន សេន ។

ជនៈ អាហ្នឹងនៅព្រំមុំ៣?

សៀនៈ មុំ៣ ព្រំដែន ឡាវ ហ្នឹងថៃ ។

អ្នកជិតខាងៈ អាហ្នឹងនៅសាន់តែនោះ ។

សៀនៈ អាហ្នឹងមិនមែននៅសាន់តែ ។

អ្នកជិតខាងៈ ទេខ្ញុំតា!

សៀនៈ អា១០០១ គេហៅទន្លេល្ពៅ ។ វាចេញពី១០០២ ទៅវាអូរលោតថ្ម, លានតាសេក, បានទន្លេល្ពៅបាន១០០១ ។

ជនៈ អញ្ចឹង វិលមកវិញពូនៅក្នុងកងប៉ុន្មានកាលហ្នឹង?

សៀនៈ អើ! កាលហ្នឹង ខ្ញុំនៅអង្គភាព៨០១ ដដែរ ក្រោមតា០៥ តាវឿន ។

ជនៈ កាលហ្នឹង ពូចូល៨០១នៅ ឆ្នាំណា?

សៀនៈ គិតទៅ៨០១ ខ្ញុំចូលឆ្នាំ៧៨ រត់យួនហ្នឹង ប៉ុន្តែទៅដល់នោះ គេរៀបចំអង្គភាពផ្សេង ប៉ុន្តែភ្លេចឈ្មោះបាត់អង្គភាពហ្នឹង ទៅដល់កន្លែងព្រំដែន អូរគ្រាង! គេហៅអង្គភាព ៧០៥ ឪពុកខ្ញុំ ។

ជនៈ ៧០៥ ឬក៏៧១៥ពូ?

សៀនៈ ៧០៥ អញ្ចឹងឯង ។

ជនៈ អញ្ចឹង ៧៨ពេលដែលរត់ហ្នឹង ពូនៅអង្គភាព?

សៀនៈ ៨០១! ប៉ុន្តែទៅដល់នោះតាចៀម គាត់ដាក់បើមិន៧០៥, ៧១៥ ។ ៧០៥ ហ្នឹងឯង! ប៉ុន្តែបកមកវិញនៅតាមព្រំដែនហ្នឹង ពួកខ្ញុំនៅអង្គភាពហ្នឹងដែរបាន បង្កើតក្រោយមក ដែលមានអង្គភាពនែក៦១២នេះ ។

ជនៈ ៦១២ របស់ តា!

សៀនៈ តាហឿន និងតា ឈាងមួយទៀត ។ បានក្រោយមកគេបង្កើតពួកខ្ញុំនេះ គេបង្កើត៦១៦ ។

ជនៈ ចុះ៧០៥ បូកជាមួយ៦១២ហ៎?

សៀនៈ អត់ទេ! ៦១៦ ហ្នឹង កងពលផ្សេង ។ កាហ្នឹងមានប្រធាន តាឃាង, តា ញ៉ន, តាវឿន, តាឡេ ។ ប៉ុនស្លាប់ហើយ តាឡេ! តា ស៊ឹម!

ជនៈ តា ស៊ឹម១ទៀត?

សៀនៈ បាទ! ៦១៦ ។ កពល៦១៦ហ្នឹង ។

ជនៈ ហ្នឹង ឈរជើងនៅឯណាវិញ?

សៀនៈ ឈរជើងនៅព្រះវិហារ៦១២ ហ្នឹង ។ តា ហឿន កងពល៦១២ ។

ថន: បាទ! អញ្ចឹងអើ តំបន់ព្រះវិហារ មាន២កងពលឈរជើង?

សៀន: ២កងពល ។

ថន: ៦១២, ៦១៦?

សៀន: បាទ!

ថន: ពីឆ្នាំណាពូមកហ្នឹង?

សៀន: ពីឆ្នាំ៨២ ។ អាហ្នឹងខ្ញុំនៅ៦១៦ណា, ៨២ហើយ ។ កាលហ្នឹងបង្កើតអង្គភាពកងពលថ្មី ។ ដល់៨៥ ខ្ញុំនៅអង្គភាពកងអន្តរាគមន៍កងពល៧៨៥ ។

ថន: កងពលអីអាហ្នឹង?

សៀន: កងពលធំរបស់តាមុត ។ ហ្នឹង តា វឿនគាត់ប្រធាន, តាគេមអនុកងពល ។

ថន: កងពល៨៥ កងពលអន្តាគមន៍កងពលធំ?

សៀន: រៀបចំអង្គភាពកងពលធំ ។

ថន: លេខប៉ុន្មាន?

សៀន: ៧៨៥ ។

ថន: អាហ្នឹងតាមុត?

សៀន: បាទ! តាមុត, តាវឿនហ្នឹង ។ ទន្លេសាប មុខកំពូល ព្រែកព្នៅ ព្រែកក្ដាមហ្នឹង ។

ថន: តាគេម ហ្នឹង ទទួលខាងទន្លេសាប?

សៀន: បាទៗ! កំពង់ធំ កំពង់ចាមទាំងអស់ ។ ហើយកាលហ្នឹង ខ្ញុំទួលនូវអង្គភាពប្រធានកងពិសេស ២៨ អង្គភាពខ្ញុំ កងពិសេស៧៨៥ហ្នឹង ។

ថន: ពូប្រធានកងពិសេសហ្នឹងហ៎?

សៀន: បាទ!

ថន: ហើយពូកាលពូនៅ៦១៦ ធ្វើនៅតួនាទីអីវិញ?

សៀន: ខ្ញុំកាលនោះ ខ្ញុំនៅកងតូច នៅកងពិសេសដែរ ។

ថន: កងតូចលេខប៉ុន្មាន? អនុសេនាតូចអី?

សៀន: អនុសេនាតូចលេខ១២ ។

ថន: ពូប្រធានអនុសេនាតូច?

សៀន: បាទ!

ថន: ពូ!និយាយថាឈរជើង នៅប្រាសាទតែម្ដង?

សៀនៈ បាទ! កងប្រាសាទ ខ្ញុំដឹងទាំងអស់ អត់បន្ទោះ?

ថនៈ ៨២ហ្នឹងពូ?

សៀនៈ បាទ! ៨២ រហូតដល់ខ្ញុំចុះធ្វើការនៅកំពង់ធំហ្នឹង ចូល៧៨៥ ខ្ញុំចុះមួយជួរសៀមរាប កំពង់ធំ, កំពង់ចាម នៅព្រែកក្តាមហ្នឹង ។ មួយជួរស្រុកបារាយណ៍,ដើងព្រៃនោះសុទ្ធតែកន្លែងខ្ញុំនៅហើយ ។ នៅបាធាយ រហូតដល់កំពង់ឆ្នាំងនោះ ខ្ញុំឈរជើងនៅនោះ មួយស្រុកជន្លកនោះ កំពង់ជន្លក, ស្រុកកំពង់លែងនោះ ។

ថនៈ មួយជួរព្រះវិហារនោះ កាលហ្នឹងអត់ទាន់មាន ព្រំដែនហ្នឹងគឺនៅខាងយើងដែរ?

សៀនៈ បាទ! នៅលើភ្នំ ។

ថនៈ អត់មានដានអី ព្រំដែនអីទេ?

សៀនៈ អត់មានទេ ។

ថនៈ ចុះថៃអី?

សៀនៈ ថៃអត់មានទេ នៅតាមភ្នំយើងពីដើម យើងទៅចម្រាក់ទៀត នៅខាងនោះអីទៀត អត់ទាន់មានថៃមកទៀត មានដី កាលនោះដីយើងទាំងអស់ ។

ថនៈ ចុះខាងព្រះវិហារមានថៃមកទេ?

សៀនៈ អត់មានទេ អាហ្នឹងរឹតតែឆ្ងាយទៀតហើយ មានតែជិតអានសេសទេដែលជិត ។

ថនៈ អានសេស?

សៀនៈ បាទ!

ថនៈ អានសេសហ្នឹង ប៉ុន្មានពីប្រាសាទហ្នឹង?

សៀនៈ ពីប្រាសាទហ៎?

ថនៈ បាទ!

សៀនៈ យី! អានសេសពីប្រាសាទឆ្ងាយណាស់ណា ៥ទៅ៦ គីឡូ អាហ្នឹងប្រកអានសេស អាហ្នឹងជិតដាងគេហើយអាហ្នឹង ។

ថនៈ អានសេសហ្នឹងជិតដាងគេហើយ?

សៀនៈ បាទ!

ថនៈ ៥ ទៅ៦គីឡូពីប្រាសាទណា?

សៀនៈ បាទ!

ថនៈ អញ្ចឹងខាងថៃ គេនៅ?

សៀនៈ ទេ! និយាយរួមពីប្រាសាទទៅថៃហ៎? ពីប្រាសាទព្រះវិហារទៅថៃហ៎?

ថនៈ បាទ! ចង់និយាយថាទាហានដែលឈរជើង?

សៀនៈ អូរនៅអានសេស ៗ ពីនេះទៅស្រះ ទល់មុខគ្នា ពីផ្សាររយើង ៗ

ថនៈ ពីផ្សាររយើង?

សៀនៈ បាទ!

ថនៈ ពីខាងថៃ ទៅខាងនោះទៅ?

សៀនៈ ទៅជិតគ្នាប្រហែល៥០ម៉ែត្រទៅ ៗ

ថនៈ ពីប្រាសាទពូ?

សៀនៈ បើពីប្រាសាទ ប្រហែលជា៥០០ម៉ែត្រ អស់ឆ្ងាយហើយ ៗ

ថនៈ ពីជើងប្រាសាទរាល់ថ្ងៃ?

សៀនៈ បាទ! ពីជើងប្រាសាទ នៅចម្ងាយប្រហែលអាមួយដួរដើមឈើខៀវៗនោះ ខាងឆ្ងាយនោះណា៎ ៗ

ថនៈ ចុះប្រៀបធៀបជាមួយបច្ចុប្បន្ន ដូចថាអាកន្លែងផ្ទះក្រហមគេហៅផ្ទះក្រហមៗ?

សៀនៈ ហ្នឹងហើយ ចម្ងាយផ្ទះក្រហមពីប្រាសាទទៅ ប៉ុន្តែឈើខ្ពស់ៗ ប៉ុនបើខ្សែត្រៀម ប៉ុនទៅមាត់ស្រះខាងនោះ ទៅមុខទៀត ៗ

ថនៈ ចុះកាលពូទៅប្រាសាទហ្នឹង ខាងថៃមានមកដាក់ទៀតទាហានដាក់អីទេ នៅមួយដួរប្រាសាទ?

សៀនៈ កាលខ្ញុំនៅអត់ដាក់ទេ វានៅបន្ទាយវានៅប្រាសាទក្រហមៗ វាអត់មានរាយទាហានទេ កាលពីដើម ខ្ញុំនៅឥលូវខ្ញុំឈប់នៅហ្នឹង តាំងពីខ្ញុំកាក់រំសាយទាហានមក ខ្ញុំទៅយកព័ត៌មាននេះមួយភ្លែតៗ ៗ

ថនៈ ប៉ុនថៃនៅខាងប្រាសាទក្រហមនេះ កាល៨២ហ្នឹង នៅនោះ?

សៀនៈ បាទ!

ថនៈ ប្រាសាទក្រហមហ្នឹង ខាងថៃសាងសង់ ឬក៏ខាង?

សៀនៈ ខាងថៃ ៗ

ថនៈ មិនមែនតាមុ៉កសាងសង់ទេ?

សៀនៈ មិនមែនទេ ៗ

ថនៈ ចុះគេថាមានផ្ទះតាមុ៉កអីមួយទៀតធ្វើសម្រាប់ទ្រ ដូចនិយាយថាធ្វើជាតូបយាមសម្រាប់អ្នកដែលដឹកឈើ ដឹកអី នៅច្រកណាវិញពូ?

សៀនៈ អត់មានទេ! មានតែអានសេស ។

ថនៈ អានសេស?

សៀនៈ បាទ! អត់មានទៅមុខទេទៀត ខាងនេះទេអ្នកដឹក ខាងរដ្ឋាភិបាលទេ បើនៅហ្នឹងបាននេះ ឈូករុនហ្នឹងបានមានរបស់តាម៉ុក នៅអន្លង់វែង ។ ខ្ញុំធ្វើឈើជាមួយថៃហ្នឹង ខ្ញុំអ្នកនាំថៃដើរ ដឹកឈើ ។ តាមផ្លូវក្រហម ខ្ញុំដើរជាមួយថៃនៅនេះ ហើយដល់បរិស័តគេ ពួកក្រុមហ៊ុនគេណា ។ ខ្ញុំនៅក្រុមហ៊ុនដែរអំណាចច្រើន អាក្រុមហ៊ុនធំជាងគេនៅស្រុកថៃនេះ ។ អាថៅកែវា ឈ្មោះ បុល ផា ។

ថនៈ ចុះពូផ្ទះក្រហមហ្នឹង អ៎ ខាងទាហានថៃហ្នឹងឈរនៅផ្ទះក្រហម ឬក៏នៅខាងមុខផ្ទះក្រហមហ្នឹងទៀត?

សៀនៈ អាហ្នឹងវានៅខាងមុខនេះតា ខ្សែត្រៀមនេះ ។

ថនៈ ប៉ុនពេលពូទៅនេះ ពីផ្លូវទៅផ្ទះក្រហមមកដើងប្រាសាទ ផ្លូវហ្នឹងមានដាក់អារបងលួសណា ។

សៀនៈ ដាក់តា!

ថនៈ មានផ្លូវហ្នឹងទេពូ?

សៀនៈ មាន! អាហ្នឹងផ្លូវជណ្តើរប្រាសាទហ្នឹង ជណ្តើររបស់ថៃ ។

ថនៈ ផ្លូវរបស់ថៃចាក់កៅស៊ូណា ពីផ្ទះក្រហមមក?

សៀនៈ ចាក់កៅស៊ូ ។

ថនៈ អញ្ចឹងមានដានផ្លូវឆ្នាំ៨២ ពូទៅដល់?

សៀនៈ មានតាំងពូយូរណាស់មកហើយ ពីមុនផ្លូវក្រហម ។

ថនៈ ផ្លូវគ្រួសក្រហម?

សៀនៈ គ្រួសក្រហម ហើយផ្លូវនេះកៅស៊ូមកដល់កន្លែងរោងយាម រោងយាមទល់មុខយើងហ្នឹងណា ។ ថៃវាហៅមោយដែង ប្រាសាទក្រហមនោះ បន្ទាយនោះវាហៅ មោយដែង ។

ថនៈ ចុះបន្ទាយនោះពូមានដឹងថា សាងសង់ឆ្នាំណាទេ ប្រាសាទក្រហម?

សៀនៈ វាសាងនោះតាំងពីខ្ញុំឈរជើងនៅឆ្នាំ ។

ថនៈ ពីមុន ឬក្រោយមកទេ?

សៀនៈ នេះមុន ។

ថនៈ មុនពេលពូមកដល់?

សៀនៈ បាទ! មុនអាច៨៥ប៉ុណ្ណឹង ។

ថនៈ ពូមកដល់៨១,៨២ហើយមែនទេ?

សៀនៈ ពេលហ្នឹងខ្ញុំមក គេកំពុងសាងសង់ទេ គេបង្កើតជាបន្ទាយ៨១, ៨២ណា ។ ប៉ុន្តែក្រោយមក ដែលរដ្ឋាភិបាល បានឡើងទៅឈរជើងនៅប្រាសាទព្រះវិហារ ដោយយើងរំដោះបាន កាលហ្នឹង យើងវាយគ្នា ហើយមិនឈ្នះខាងរដ្ឋាភិបាល វាកើតមិនដឹងតាំងពីឆ្នាំណា ប៉ុន្តែកើតតែបន្ទាយទេ ។

ថនៈ ៨២ហ្នឹងខាងរដ្ឋាភិបាលឈរជើងខាងប្រាសាទព្រះវិហារ មិនមែនប្រាសាទក្រហមទេ?

សៀនៈ បាទ! នៅហ្នឹងប្រាសាទតែម្តង ។

ថនៈ ឈរជើងនៅប្រាសាទតែម្តង?

សៀនៈ បាទ!

ថនៈ ខ្មែរក្រហមវាយយកបានព្រះវិហារនៅឆ្នាំណា?

សៀនៈ ឆ្នាំប៉ុន្មាន!

ថនៈ ៨២ហ្នឹងហេ៎?

សៀនៈ អត់ទេ ។ ឆ្នាំប៉ុន្មានទេដែល មុនអ៊ុនតាក់តិច យើងវាយឈ្នះ មុនអ៊ុនតាក់ចូល ។

ថនៈ ៩១ហេ៎?

សៀនៈ ៩០,៩១ហ្នឹងឯង តាមមើលដែលយើងវាយឈ្នះ ។ ភ្លេចបាត់ហើយហ្នឹង អត់បានកត់ទុកទេ វាយប្រាសាទព្រះវិហារឈ្នះ ។

ថនៈ អញ្ចឹងពេល៨១, ៨២ហ្នឹង ពូគាត់និយាយថាចល័តទេ មិនមែនទីតាំងទេ?

សៀនៈ ចល័តខ្ញុំតាមព្រំដែនហ្នឹង ។ តាមព្រំដែនដើរបើកច្រក ឃ្លាំងអង្ករទាំងអស់ហ្នឹង ថៃវាដឹកអង្ករមក ។

ថនៈ បាទ! អញ្ចឹងបន្ទាយថៃ មានតែបន្ទាយទេ?

សៀនៈ បាទ! មានតែបន្ទាយទេ វាមិនមកព្រៃដូចរាល់ថ្ងៃទេ អីចឹងកាលនោះ វានៅភូមិវានោះដូចថាភូមិ ចេះបន្ទាយវាខ្ពស់ប្រហែលជា១០០ម៉ែត្រអីចឹង បន្ទាយទាហានកាលហ្នឹង ។

ថនៈ នៅម្តុំដូចថា ប្រាសាទក្រហមតែម្តងគេហៅភូមិវិញ?

សៀនៈ បើមួយជួរប្រាសាទក្រហមតែម្តងវានៅ តាំងពីអើយមកណា អាហ្នឹងគេហៅភូមិស្រល់ ។

ថនៈ នៅខាងថៃ?

សៀនៈ នៅខាងថៃ ភូមិស្រល់ ។

ថនៈ ភូមិស្រល់ នៅឃុំអីវិញ?

សៀនៈ ឃុំស្រល់ដែរ ។

ថនៈ ស្រុកស៊ីសាកេត?

សៀនៈ ស្រុកខាន់ស្វាក់ ។

ថនៈ ខាន់ស្វាក់?

សៀនៈ ខាន់ស្វាក់ ។ អាហ្នឹងព្រំប្រទល់ស្រុកណាំយឿនណា៎ ព្រំប្រទល់គ្នា មកកើតចេះខាង ខាងណាំយឿន ខាងខេត្តខបុន ។ អានេះស៊ីសាកេតព្រំប្រទល់គ្នា ។

ថនៈ អានេះប្រាសាទហ៎ពូ?

សៀនៈ បាទ!

ថនៈ អញ្ចឹង អានេះមានស្រុកណាំយឿនទៀត?

សៀនៈ ដាប់ហ្នឹង កែងហ្នឹង តាមហ្នឹងកែងបី មកខាងកើតមកភូមិរទ្ធញ៉ាង អាហ្នឹងព្រំប្រទល់ទេខេត្តណាំយឿន ។

ថនៈ ព្រំប្រទល់ខេត្តតែម្តង?

សៀនៈ ស្រុក ។ បាទ! ខេត្តខបុននោះ ។

ថនៈ អញ្ចឹងបូ៨១, ៨២នេះខាងរដ្ឋាភិបាលទេ ឈរជើងនៅលើប្រាសាទ?

សៀនៈ បាទ!

ថនៈ ប៉ុន្តែពូចល័តដូចថា ចល័តទៅតាមជួរ?

សៀនៈ អាហ្នឹង ខ្ញុំឈប់ចល័តហើយ ដល់ក្រោយមកពី៨១, ៨២ណា,៨៤,៨៥ហ្នឹង ខ្ញុំនៅនោះនៅទន្លេស្លា លែងនៅព្រំដែនហើយ ។ អាហ្នឹងនៅតែ៦១២ទេ, ៦១១ គេឈប់នៅហើយ គេទៅនៅខាងស្ទោង, ខាងកំពង់ធំ ។ នៅតែ៦១២ នៅខាង៩១២ ។

ថនៈ ៦១២, ៩១២ ។ នៅឈរជើងនេះដដែរ?

សៀនៈ បាទ! ៩១២ គេឈរនៅខាងសៀមរាប ហើយ៦១២ គេឈរនៅខាងនេះ ។ ៦១៦ គេចុះនៅខាងកំពង់ធំ ខាងលើថ្នល់ មួយជួរស្ទោង ក្រយា ។ បើខាងខ្ញុំ ខ្ញុំរត់រហូតតាំងពីកំពង់ចាមនៅក្រចេះ ដល់កំពង់ឆ្នាំងនោះ ពួកខ្ញុំ, ពួកអន្តរាគមន៍ ។ ប៉ុន្តែទីតាំងពួកខ្ញុំធំនៅទន្លេនេះឯងនៅទន្លេ ហើយនៅជើងព្រៃនៅបាធាយ ជួរជំឡូង, មួយជួរទ្រាល, មួយជួរស្គន់ ។

ថនៈ អីចឹង ពូដែលឈរជើងស៊ុបតែម្តងពេលវាយឈ្នះខាងរដ្ឋាភិបាលនៅខាងព្រះវិហារ ពូថាជិតនាំ ៩០, ៩១ ពូនៅឈរជើងព្រះវិហារតែម្តង?

សៀនៈ កាលហ្នឹង ខ្ញុំនៅនេះ ខ្ញុំអត់បានចូលដល់ព្រះវិហារទេ ខ្ញុំផុតពីដីតែបើកច្រកហើយ ខ្ញុំចុះមកធ្វើការខាងក្នុងមួយជួរខេត្តព្រះវិហារហ្នឹង នៅខាងស្រុករវៀង, ជ័យសែន, ជាំក្សាន, ស្រុក!

ថនៈ ចុះពូថា នៅខាងអ៊ីហ្វៀននៅខាង និយាយថាខាងថៃណា អាកន្លែងផ្ទះក្រហមគឺមាន ថៃមកបោះកង់ទ័ព នៅហ្នឹងមានវរសេនាតូច?

សៀនៈ ខ្ញុំស្គាល់ទៀត ហើយបានភ្លេចវរសេនាតូចឈ្មោះ ទស្សាមុត ។

ថនៈ ខាងថៃណា?

សៀនៈ បាទ!

ថនៈ ឥលូវថាឡើងផ្កាយមួយ ។

សៀនៈ សាមុត ហើយណារុង ។

ថនៈ ណារុង?

សៀនៈ បាទ!

ថនៈ ណារុងហ្នឹង ថាផ្កាយ១ហ៎?

សៀនៈ បាទ!

ថនៈ អាហ្នឹងរបស់ តាំងពីជំនាន់ខ្មែរក្រហមមក?

សៀនៈ បាទ! យូរហើយ ។

ថនៈ អាហ្នឹងវរសេនាតូច ឬវរសេនាធំ?

សៀនៈ ពីមុនវរតូចទេណារុង ប៉ុន្តែឥលូវនេះ ។

ថនៈ បោះនៅកន្លែងប្រាសាទហ្នឹងហ៎?

សៀនៈ បាទ! នៅមោយដែង ។ អាហ្នឹងហើយមេធំនោះ ។

ថនៈ ឆ្នាំប៉ុន្មានពូ មកបោះហ្នឹង?

សៀនៈ ឆ្នាំ ៨១,៨២ ហ្នឹង បងណារុង ។ តាសឿន គាត់ស្គាល់ គាត់នៅជាប់តែ គាត់នៅឯព្រំដែនហ្នឹង ។

ថនៈ គាត់ស្គាល់ច្បាស់ ឬអត់ស្គាល់ទេ?

សៀនៈ ស្គាល់ច្បាស់តែម្តង ។ បងកុសលនេះ តាហឿននេះ គាត់ស្គាល់ច្បាស់នៅព្រំដែននេះ បើខ្ញុំចល័ត ខ្ញុំនៅពីដំបូង ដល់ក្រោយៗមក ខ្ញុំមកនៅ ប៉ុនដល់ក្រោយមកនេះ ខ្ញុំមកនៅក្រោយនេះទៀត ។ ខ្ញុំមកកាន់វិទ្យុ បានមកជួបកុសល ហើយតាហឿន ហើយប៉ុន្តែសភាពការព្រំដែនកាលហ្នឹង ដឹងតែតាមរាយការណ៍ តាមអី ចុះខ្ញុំកាន់វិទ្យុទាក់ទងនោះ តាមអង្គភាពនោះ

គេវាយការណ៍នោះ ខ្ញុំចេះតែកត់ទុកទៅណា ។ កាលនោះ ខាងវិទ្យុទាក់ទងខ្មែរក្រហម ។ អន្តភាពណាវាយបាន ប៉ុន្មានស្លាប់របួស ។

ថន: អីចឹងវរសេនាតូចនោះ ពូអត់ដឹងលេខប៉ុន្មាន ប៉ុន្មានទេ?

សៀន: អត់ដឹងទេ! ទាល់តែតាហឿន បើសួរថុនបានច្បាស់ ។ ថុន ញ៉ែប ស៊ីថុន?

ថន: អាហ្នឹង គាត់នៅឯណាវិញ?

សៀន: នៅលេខ៨ ផ្កាយ៣ ។

ថន: ញ៉ែប ស៊ីថុន?

សៀន: ហ្នឹង ហើយ គេត្រូវជាមួយលោកណារុង ណាអី គេដឹងច្បាស់ ព្រោះគេត្រូវគ្នាជាមួយលោកណារុងហ្នឹង ព្រោះគេទៅប្រចាំខួបប្រាំង ខួបវស្សា រហូតដល់ផ្តាច់ខ្លួននៅលើប្រាសាទ ។ វាអ្នកទទួលខុសត្រូវតាំងពីស្បៀងអាហារនៅប្រកកងពល៦១២ហ្នឹង ។

ថន: ឥលូវគាត់នៅណាវិញ?

សៀន: នៅកងពលលេខ៨ កូនប្រសារតាស៊ិន់មួយដែលចូលក្រុមប្រឹក្សាស្រុក ។ អាមួយចូលព្រឹកម៉ិញពួកអាវធំ ។

ថន: កូនប្រសារតាស៊ិន់ ហេ៎?

សៀន: បាទ!

ថន: គាត់ផ្កាយបីហេ៎?

សៀន: ផ្កាយបី ។

ថន: គាត់នៅកងពលលេខប៉ុន្មាន?

សៀន: កងពលលេខ៨ នៅជាមួយយឹម ពឹម ។

ថន: អីចឹងបើផ្ទះក្រហមនោះ បើតាមពូដឹង ប្រហែលក្រោយទេ ៨១,៨២ទេ?

សៀន: ព្រោះកាលដែលដើបើកប្រកនោះ ខ្ញុំឆ្លងកាត់នែក៎ មួយជួរប្រាសាទហ្នឹង វាមានតែបន្ទាយទេ វាមានតែនៅយ៉ មានត្រង់សេមានតែផ្ទះធម្មតាទេ ឥលូវវាបង្កើតផ្ទះស្អាតៗណាស់ ដែលវាហៅមោយដែងៗ ។

ថន: អីចឹង ផ្ទះហ្នឹង មិនមែនជាផ្ទះតាម៉ុក?

សៀន: អត់ទេ! មិនមែនជាផ្ទះតាម៉ុកសាងសង់ទេ ។

ថន: ចុះកាលហ្នឹង ផ្លូវពីប្រាសាទមាននៅ?

សៀន: វាមានត្រឹម មោយដែង គ្រួសក្រហមណា៎ ។

ថនៈ   អីចឹង វាឡើងតាមថៃទៅ ឡើងតាម?

សៀនៈ ចេញពី មោយដែង ទៅវាលថ្នក់ ពិបាកធ្វើផ្លូវថ្មកាល ។

ថនៈ   ចេញពីមោយដែងមកខាងយើង ឬមកខាង?

សៀនៈ មកខាងយើង ខាងជើងផ្សារ ។

ថនៈ   អញ្ចឹងផ្លូវមោយដែងហ្នឹង ចេញពីផ្លូវក្រហម ហើយអាពីផ្លូវមោយដែងមកប្រាសាទ ផ្លូវថ្ម ។

សៀនៈ ថ្មវាដុះពីធម្មជាតិហ្នឹងណា៎ ថ្មដា ។

ថនៈ   អត់មានផ្លូវទេ គឺថ្មតែម្តង?

សៀនៈ ថ្មក្រាលស្អាតថែស ហើយចេញផុតពីថ្មមក ពីអូរមកបានព្រែក ហើយបានពីព្រែកហ្នឹងបាន រយោង (ស្តាប់ពុំបាន) ។

ថនៈ   អញ្ចឹងផុតមក ផុតមកកន្លែងមោយដែង ។

សៀនៈ មកកន្លែងថ្មតែម្តង ។

ថនៈ   សព្វថ្ងៃហ្នឹង ហ៎ពូ?

សៀនៈ សព្វថ្ងៃវាកើតជាកៅស៊ូបាត់ហើយ ។

ថនៈ   អត់ទេ! និយាយថាអត់មានរំកិលទៅមុខទៅក្រោយណា ទៅដល់បច្ចុប្បន្នតំបន់ដុះក្រហមរាល់ថ្ងៃ?

សៀនៈ អត់មានទៅណាទេ នៅហ្នឹងដដែល វារំកិលដែរ ខ្សែត្រៀមហ្នឹង ខ្សែលឿង ពីដើមវាអត់មាន ដាក់ខ្សែលឿងទល់មុខយើងទេណា វានៅហ្នឹងបន្ទាយយើងធម្មតាទេ ។

ថនៈ   អីចឹងផុតអាផ្លូវក្រហមនោះ ផុតត្រឹមមោយដែងនោះទេ?

សៀនៈ បាទ!

ថនៈ   ហើយក្រោយពីមោយដែងនោះថ្មទេ?

សៀនៈ បាទ!

ថនៈ   មិនមែនចាក់កៅស៊ូដូចបច្ចុប្បន្នទេ?

សៀនៈ អត់ទេ! ហើយបន្ទាយវាដូចយើងនៅសាលាស្រុកធម្មតា មិនមែនដូចឥលូវ បើឥលូវដាក់ខ្សែត្រៀម ដាក់ខ្សែត្រៀមពីត្រឹម ឧទាហរណ៍ថាយើងមកលិចអញ្ចឹងណា មកចេះវាជ្រោះដល់អីចឹងវាមកទល់មុខគ្នា មើលគ្នាឃើញហ្នឹង យើងហ្នឹងវា ។ វាមិនបាន៥០ជាងពីគ្នា ។

ថនៈ   ចុះវាមានផ្លូវចាក់ពីមោយដែងហ្នឹងមកប្រាសាទហ្នឹងប្រហែលជាប៉ុន្មានយើងរៀបចំ?

សៀនៈ ខ្ញុំអត់ដឹងដែរ ព្រោះដល់ខ្ញុំឈប់ កាត់រំសាយពីទាហានមក ខ្ញុំទៅលេងម្ដងៗ ខ្ញុំអត់ដឹង បើកាលខ្ញុំនៅ ខ្ញុំវាកាត់រំសាយពីទាហានយូរហើយ ។ កាត់រំសាយរហូតដល់ខ្ញុំ រត់ទៅជិរុំទៀតរបស់ផ្ដាច់ខ្លួននេះចុះមកក៏មិនទាន់កែទេ ដល់ខ្ញុំទៅលេងពេលក្រោយវាប្លែក ប្លែកទាំងអាផ្លូវយើងចាស់នេះ ផ្លូវយើងតាំងពីនេះ ទៅពីខាងថៃនោះ ប៉ុន្តែខ្ញុំបានទៅលេងនៅផ្សារវាម្ដងដែរនៅផ្សារនៅទំនប់ក្បែរគ្នាណាទៅជាមួយប្រពន្ធខ្ញុំអី ទៅដល់ភូមិ ។

ថនៈ ហើយពូអាផ្លូវយើងរាល់ថ្ងៃ ឡើងតាមឈូកថ្មី ឡើងតាមខ្មែរ, តាមវាលឥន្ទ្រី, តាមប្រាសាទកែវសិខាហ្នឹង កាលហ្នឹងមាននៅ កាលពូ?

សៀនៈ មានហើយ ។

ថនៈ ប៉ុន្តែមិនមែនជាផ្លូវថ្មទេ?

សៀនៈ ថ្មទេ ។

ថនៈ ឡានអីអាចឡើងរួចទេ?

សៀនៈ រួចទេ ។

ថនៈ ឡើងអត់រួចទេ ។

សៀនៈ ខ្ញុំដឹកអង្ករឡើងប្រាសាទ ខ្ញុំបើកអាត្រាក់ ខ្ញុំឡើងលេខមួយហ្នឹង អង្ករពីរបេ បីបេ ។ អាបាវខ្មៅថៃហ្នឹង ។

ថនៈ ជិនាន់៨១,៨២ហ្នឹង?

សៀនៈ អត់ទេ! ជិនាន់៩៧,៩៨, ២០០០នេះ ។

ថនៈ ២០០០អត់ទាន់ឡើង?

សៀនៈ ២០០០ ឡើងហើយ! ឡើងទៅធ្វើហើយ យើងធ្វើ! ប៉ុន្តែកាលនោះយើងធ្វើ វាអត់ល្អថ្មវាអង្កក់ អង្កើមនោះណា៎!

ថនៈ ៩៧,៩៨ហ្នឹងហ៎?

សៀនៈ បាទ! វាបើកឡើងទៅ ទាំងវេទនា ។

ថនៈ តាម៉ុក គាត់ធ្វើលើផ្លូវចាស់រួចហើយហ៎?

សៀនៈ ផ្លូវតាម៉ុក ធ្វើមុនគេតែម្ដង ។

ថនៈ ផ្លូវថ្មីតែម្ដងរាល់ថ្ងៃ អាផ្លូវធ្វើរាល់ថ្ងៃ ធ្វើតាមផ្លូវតាម៉ុក តាមផ្លូវទៅតាមតាម៉ុក ។

សៀនៈ បាទ!

ថនៈ អ៊ូអញ្ចឹង ពីមុនអត់ផ្លូវមានឡើងទេ?

សៀនៈ អត់ទេ! អត់មានទេ! ដូចអន្លង់វែងអញ្ចឹងអត់មានផ្លូវឯណា មិនផ្លូវតាម៉ុក ធ្វើតាមផ្លូវហ្នឹងបណ្ដោយ ។ ផ្លូវឡើងប្រាសាទព្រះវិហារនៅតាមផ្លូវតាម៉ុក ចាស់ដែរ ប៉ុន្តែបីមុនវាលំបាក ។

ថនៈ អញ្ចឹងពីមុនមកជិតទាន់៨០ជាង យើងឡើងមកពីថៃទេ តាមថៃ?

សៀនៈ អត់ទេ! ឡើងទៅពីខ្មែរ ។ ឡើងពីខ្មែរឡើងផ្លូវថ្មើរជើង ។

ថនៈ ផ្លូវថ្មើរជើង?

សៀនៈ បាទ! ឡើងតាមដើរ ឡើងលើស្ពានអង្គរ ហើយជណ្ដើរបុរាណ ។ ឥលូវលែងព្រួយហើយផ្លូវស្អាត ចាក់បេតុង ។

ថនៈ ចុះពូមករស់នៅត្រពាំងប្រាសាទនេះឆ្នាំប៉ុន្មានពូ?

សៀនៈ ឆ្នាំដែលផ្ដាច់ខ្លួនហ្នឹង ។

ថនៈ នៅ៩៨?

សៀនៈ បាទ!

ថនៈ កាលហ្នឹងពូនៅឯណា?

សៀនៈ កាលហ្នឹង ខ្ញុំនៅជិរុំ ។ អ៊ំ កាលមុនខ្ញុំនៅអូរស្មាយ ខ្ញុំនៅច្រើនណាស់ពីមុន នៅជាមួយប្រកឈូករុននេះ ចេញមកដល់យើងវាយគ្នាជាមួយរដ្ឋាភិបាល អាហ្នឹងឈប់យួនហើយណា ខ្ញុំទៅនៅឯអូរស្មាយ ទៅនៅឃុំអូរស្មាយ ចេញពីហ្នឹងខ្ញុំជាមួយបងកុសលទៅនៅ មួប់ទោងយើងនេះ ។ មួប់ទោងអន្លង់វែងយើងនេះ ទៅនៅហ្នឹងគាត់ គាត់ទៅនៅ៩១២ ។ ដល់នេះខ្ញុំកាន់វិទ្យុឲ្យគាត់ ចេះតែតាមគាត់ទៅណា បែកគ្នាពីអង្គភាព៦១២ ។ ខ្ញុំចេញពី៧០៥មក ខ្ញុំធ្វើប៉ូលិស ។ ដល់ខ្ញុំចេញពីប៉ូលិសមកជិរុំទៅ ខ្ញុំខ្ជិលអាណិតប្រជាពលរដ្ឋ វាគ្នាចេញចូលហើយចេញពីក្រៅ ជិរុំឲ្យខ្ជិល ចេញពីប៉ូលិសហើយ ខ្ញុំធ្វើប៉ូលិសជិរុំនេះណា ដាច់ជើងអីចឹងឯងណា ។

ថនៈ កាលហ្នឹងជិរុំ នរណាអ្នកគ្រប់គ្រង?

សៀនៈ ជិរុំយើងអ៊ំត្រាវហ៎?

ថនៈ បាទ!

សៀនៈ ឈ្មោះអីទេ ភ្លេចបាត់ហើយ ។ មានប្រធានជិរុំ ដូចជាអត់មានទេ ដូចថៃ មានតែសង្កាត់ ។ សង្កាត់ៗហ្នឹងខ្មែរទាំងអស់ ។

ថនៈ កាលហ្នឹងខ្មែរក្រហមអ្នកគ្រប់គ្រង ឬក៏អង្គការ?

សៀនៈ អត់ទេ! ខ្មែរក្រហមអ្នកគ្រប់គ្រង ។ ខាងអង្គការ UN ក្រៅពីហ្នឹងប្រធានសង្កាត់ គឺខ្មែរ ។

ថនៈ អញ្ចឹង ពូមកខាងប៉ូលិស ឆ្នាំប៉ុន្មាន?

សៀនៈ ខ្ញុំចេញឆ្នាំ៩២ ខ្ញុំចេញពី ខ្ញុំមកនៅ៩១២ ខ្ញុំនៅជាមួយហឿន។ នៅជាមួយហឿន ខ្ញុំបើកអាត្រាក់ បើអាត្រាក់ភ្ជួរ។

ថនៈ ៩១២ណ៎ពូណ៎?

សៀនៈ បាទ!

ថនៈ ចុះពូមានរបួស ពេលបើកអាត្រាក់ហ្នឹងហ៎?

សៀនៈ អត់ទេ! ខ្ញុំរបួសនៅឯទន្លេសាប មុខកំពូល។ ខ្ញុំមកនៅជាមួយហឿនហ្នឹង ខ្ញុំមកកាន់ខាងប៉ូលីសទៀត ប្រធានប៉ូលីស ខ្មែរក្រហម។

ថនៈ ខ្មែរក្រហមបង្កើតប៉ូលីសដែរ?

សៀនៈ បាទ!

ថនៈ បង្កើតយ៉ាងម៉េចទៅប៉ូលីសហ្នឹង?

សៀនៈ បង្កើតសម្រាប់គ្រប់គ្រងមើល ការខុសត្រូវអី។

ថនៈ អាហ្នឹងដាច់ពីកងទ័ព ឬយ៉ាងម៉េច?

សៀនៈ ដាច់ពីកងទ័ពដូចថា ផ្នែករៀបចំសណ្ដាប់ធ្នាប់ អ្នកខាងក្រោយ កុំឲ្យមានមានអំពើហឹង្សាកុំឲ្យមានលួចបប្លន់អីអញ្ចឹងទៅណ៎។ ខ្ញុំមកបានបងវណ្ណកុសល គាត់ហៅមកកាន់វិទ្យុទាក់ទងជាមួយគាត់។

ថនៈ ឆ្នាំប៉ុន្មាន?

សៀនៈ បន្ទាប់ពីឆ្នាំហ្នឹង។

ថនៈ បន្ទាប់ពីឆ្នាំ៩២?

សៀនៈ បាទ! ខ្ញុំមកកាន់ វិទ្យុជាមួយគាត់រហូត រត់ទៅនៅជំរុំ។

ថនៈ ជំរុំណាវិញ?

សៀនៈ រត់ទៅជំរុំឆ្នាំ ប៉ុន្មានទេ អាចុងក្រោយនេះ៩៧។

ថនៈ ជំរុមអីវិញ?

សៀនៈ ជំរុំហួណយ។ ជំរុំក្នុងឃុំថៃ ហៅថាឃុំក្របិល ស្រុកថៃណា។

ថនៈ ឃុំអីវិញ?

សៀនៈ ឃុំក្របិល។

ថនៈ ស្រុកអីវិញ?

សៀនៈ ស្រុកខាន់, អាស្រុកកូស៊ីន។

ថនៈ   កូស៊ីន! ខេត្ត?

សៀនៈ កូស៊ីន, ខេត្តស៊ីសាកេត ។

ថនៈ   ជំរុំហ្នឹង ខាងណាគ្រប់គ្រង?

សៀនៈ ខាងខ្មែរក្រហម ។

ថនៈ   អញ្ចឹងពូនៅហ្នឹង រហូតដល់សមាហរណកម្មតែម្តង?

សៀនៈ បាទ! ដល់សមាហរណកម្ម ហើយចុងក្រោយគេបន្ទស់ហើយខ្ញុំ សមាហរណកម្ម ៩៨ហ្នឹង ។

ថនៈ   ចុះកាលពីប្រទូស ប្រទាស់គ្នាតាម៉ុក ជាមួយ ជិនាន់ប៉ុលពតនោះ?

សៀនៈ ហ្នឹងហើយ! រត់ឡើងទៅលើ ៩៨ ។ ប៉ុន្តែ ចុះមកវិញ ចុះមក៩៨វិញដដែរ ។

ថនៈ   អញ្ចឹងពូនៅក្នុងកងពល៩២១ដដែរ?

សៀនៈ ដល់នេះ ចុងក្រោយនេះដែលប្រទូសប្រទាស់ ខ្ញុំនៅ៩១២ កងពលតាគង់ ។

ថនៈ   អាហ្នឹងខាងតាម៉ុក ឬខាង?

សៀនៈ ខាងតាម៉ុក ។

ថនៈ   ខាងខ្មែរក្រហម?

សៀនៈ ខាងខ្មែរក្រហម ។

ថនៈ   ខាងប៉ុល ពត?

សៀនៈ បាទ! ខាង ប៉ុល ពត ។

ថនៈ   ចុះប្រទូសប្រទាស់គ្នា មានបែងចែកគ្នា ខាងនេះទៅនោះ ខាងនោះទៅនោះ ។

សៀនៈ ចាំមើលណា! ខាងតាហឿន ខាងរដ្ឋាភិបាល ខាងនេះណា ។ ខាងខ្ញុំ ខាងតាម៉ុក ខាងតាគេម ខាងតាគង់ ខាងលោកបងសុង រត់ទៅខាងតាម៉ុកទៅលើភ្នំ ជំរុំហ្លួណយ ព្រោះតាហឿន ផ្តាច់ខ្លួនចេញមុន ។

ថនៈ   ចុះពេលប្រទូសប្រទាស់គ្នាជាមួយ ប៉ុល ពត ជាមួយពួក?

សៀនៈ ពួកនោះ មានទាន់រត់ទាំងអស់គ្នា ។

ថនៈ   នៅឡើយទេ?

សៀនៈ បាទ! ពួកខាងនេះនៅខាងនេះ ហើយពួកអន្លង់វែងនៅខាងអន្លង់វែង ។ ប៉ុនគ្រាន់តែបែកចែកគ្នា មួយខាងតាសុន សាន មួយខាងតាម៉ុក ។ តា០៥ ហើយនឹងខាងប៉ុល ពតណា ។ខាងតាម៉ុក នោះខាងអន្លង់វែង ខាងតាគេម តាគង់ ឲ្យតែខាងអន្លង់វែងខាងតាម៉ុក ខាងនេះខាងប៉ុលពត ។

ថនៈ   ចុះមានដឹងហេតុការណ៍អីបែកបាក់គ្នា?

សៀនៈ បើលោកគ្រូឯកសួរតាកុសល គាត់ដឹងច្បាស់ណាស់ ព្រោះគាត់មានរឿង មានរាវច្រើនៗ តាកុសលនៅមិនបានដោយសារ ចោទគាត់ទេ បើតាមខ្ញុំយល់ មុនស្បូគាត់(ស្តាប់ពុំបាន) ។ អ្នកណាត្រូវផាប់ រស់ សួរបងកុសលណា ។

ថនៈ ហើយចុះនរណាដែលសម្លាប់ សុន សេន?

សៀនៈ តាសុន សេន, តា០៥ តាសារឿនតែប៉ុណ្ណឹង មិនមែនតាសារឿនទេ កូនចៅគាត់ ។

ថនៈ កូនចៅគាត់ហ៉េ ដែលសម្លាប់សុន សេនហ្នឹង ពូនៅណា?

សៀនៈ ខ្ញុំនៅមុខហ៉ ។

ថនៈ អត់ដឹង?

សៀនៈ អក្ខរក្សរបស់តាកុសល ។

ថនៈ រ៉ាន់ កុសលហ្នឹង?

សៀនៈ កាន់បាយ កាន់កាំសៀវ, ទឹកក្តៅ, ទឹកត្រជាក់ ។ កាលនោះ ខ្ញុំពីរនាក់វ៉ា គេជិតសម្លាប់វ៉ា រត់ទៅនោះ រត់!

អ្នកជិតខាងៈ ព្រៃឧគីឡូទម្រាំបានដល់ ភូមិសាកេតនេះ ទៅដល់ហ្នឹងផាប់ខ្ញុំ ។

ថនៈ ខាងណាទៅអាហ្នឹង ខាងប៉ុល ពត?

អ្នកជិតខាងៈ ខាងណា ខាងនេះឯង ខ្ញុំលនិយាយ ផលូវត្រូវគ្នាអស់ហើយ ។

អ្នកជិតខាងៈ គេរកសម្លាប់ខ្ញុំ ពីរនាក់បងសៀននេះ ។ រត់ព្រៃឧគីឡូនោះ រត់មកដល់ភូមិតាកេតនោះ ឯង រកសម្លាប់ខ្ញុំ នៅលើប្រឡាយថ្មី ។

ថនៈ ក្នុងព្រឹត្តិការណ៍ហ្នឹងណ៎ពូណ៎? ខ្ញុំដឹងអត់សូវច្បាស់ទេ ជាមួយសុនសេន ជាមួយប៉ុល ពតអីអញ្ចឹង?

សៀនៈ ដឹង! ប៉ុនអត់ច្បាស់កាលហ្នឹង និយាយទៅខ្លាចខុស គេវ៉ាយ គេថាគេវ៉ាយ ។

អ្នកជិតខាងៈ បងកុសលនេះធ្វើនាយក(ស្តាប់ពុំបាន) ។

ថនៈ សុន សេន មេរបស់គាត់ដែរ?

អ្នកជិតខាងៈ ចុះអារឿងតាសុនសេន មិនសម្លាប់ប្តី សម្លាប់ប្រពន្ធ ហើយរំលោភកូនទៀត (ស្តាប់ពុំបាន) ថៃថត! ប្រពន្ធគាត់ស្លាប់នៅព្រៃគុយ ។

ថនៈ ព្រៃគុយនៅឯណាវិញ?

អ្នកជិតខាងៈ ព្រៃគុយយើងនៅភ្នំដាំ នេះស្លាប់ភ្លាមៗ ទៅមើល ប្រពន្ធតាកុសលមេ ។ គាត់អ្នកដាំបាយឲ្យប៉ុល ពត ។

ជនៈ ពូនៅជាំបាយឡប៉ុល ពត?

អ្នកជិតខាងៈ អត់ទេ! ប្រពន្ធគាត់ៗ ប្រពន្ធតាកុសលហ៎?

ជនៈ បាទ! បានទៅមើលដែរ ទៅមើលពេលស្លាប់អី?

សៀនៈ ទៅមើលអី ប៉ុនគេយករូបថតមកឲ្យ ។

អ្នកជិតខាងៈ ហ៎ ទៅមើល ស្លាប់នៅជាំ ស្លាប់យប់ ។

សៀនៈ អត់ទេ! យើងនៅក្រុងសាន់តេ មិនយករូបថតមក ។

អ្នកជិតខាងៈ ឡើងទៅលើមកវាយនេះ វាយនេះមួយកង ៗ យើងវាយ! យើងវាយផ្អែតមែនណា (ស្តាប់ពុំបាន) ខ្ញុំនេះវាយ ផ្តាច់ ។

ជនៈ វាយដាច់ កាលជំនាន់៩០?

សៀនៈ ៩២!

អ្នកជិតខាងៈ មួយសារនោះ ខ្ញុំវាយដាច់នោះ អ៊ូងាប់ច្រើនណាស់ ងាប់៤នាក់ ។

ជនៈ ងាប់ខាងខ្មែរក្រហមហ៎?

សៀនៈ ងាប់ខាងខ្មែរក្រហម ងាប់៤នាក់ ។

ជនៈ ចុះខាងរដ្ឋាភិបាល?

សៀនៈ ងាប់តែម្តងឃើញឈាម ត្រង់ពើយតាដៀវ ឃើញតែឈាម ។

ជនៈ ៩០ ប៉ុន្មាន?

សៀនៈ មួយសារហ្នឹង មិនដឹង៩០ប៉ុន្មានទេ ដែរយើងវាយដាច់នោះ ប្រហែល៩២ទេដឹង ។

ជនៈ មុនបោះឆ្នោត ៩៣ហ្នឹងហ៎?

សៀនៈ ហ៎! មុនអុនគាក់ៗ អាមួយសារនោះ ប្រធានវាបុកគ្នា ចុះមិនមែនយួនឯណា ខ្មែរនិងខ្មែរតែម្តង មកដល់គ្នា ។

អ្នកជិតខាងៈ សួរបងកុលបានចាំ គាត់មេបញ្ជាកា វាយមួយសារហ្នឹងងាប់អាលយ ។

សៀនៈ កាលហ្នឹង ងាប់អាលយ ងាប់អាគ្រុំ និរសារតាសុន ហ្នឹង អាដេន ៗ ហ៊ូ! អានោះវាវាយសាហាវណាស់ អាគ្រុំ ៗ មិនដឹងស្លាប់ប៉ុន្មានទេលោកអើយលោក ។ ឲ្យតែអ្នកយកប្រពន្ធទៅ ងាប់ទាំងអស់តា ៗ កូនចៅគាសល់ងាប់មួយ រត់ហ្នឹងគេ ៗ អាណាហ៊ានរត់បាញ់ចោល ។

ជនៈ អញ្ជឹងពូ ខ្ញុំអស់អីសួរពូហើយ អគុណពូច្រើនណាពូណា ។

សៀនៈ បាទៗ! អគុណ ៗ "ចប់"